ទស្សនាវដ្ដី លេខ ១០

ជ្រកដ្ឋានដ

មជ្ឌលវប្ប.ចេតិយ.ពុទ្ធសាស្ត្រ

Don Offert par M.
IMPRIMERIE VIRIYA PRENH

មាតិការឿង

បណ្ណាធិការ	វិចារណកថា	ទំព័រទី	១
	ដំណឹងសាសនា	,,	៣
មហាវេជ្ជ-ទិត	ស្ថានការណ៍នៅសហភាពភូមា	,,	៧
ភិក្ខុ អាំ-ស្ងួន (ហៅ ហម)	សាសនាដេន និងពុទ្ធសាសនា	,,	១៥
ភិក្ខុ លី-គឹមឡុង	ពិធីបុណ្យធ្វើឆ្នាំសង្ហ្ក្រាន	,,	២០
ព្រះពុទ្ធវង្ស ភៅ-ស៊ីម	ឫកណានិវេសន៍	,,	២៤
ព្រះគ្រូប្ដីត្ដមរាលី អ៊ូ-ដេវ	ធនញ្ញយបណ្ឌិត	,,	២៨
លោក ផៃ-ដុន	ជ័យប្រាជ្ញ (ត)	,,	៣២
	ពាក្យថ្នាមបស់គណកម្មការវៀតណាម	,,	៣៧
ភិក្ខុ អាំ-ស្ងួន (ហៅ ហម)	ចេនារ៉ាលាសរ៉ាក្យកាសាអង់គ្លេស	,,	៣៨

ដំណៃតម្លៃ

ក្នុងប្រទេស			ក្រៅប្រទេស		
៦ ខែ	១ ឆ្នាំ	១ក្បាល	៦ ខែ	១ ឆ្នាំ	១ក្បាល
៥០រ០០	១០០រ០០	១០រ០០	៦០រ០០	១២០រ០០	១៣រ០០

អ្នកទទួលឲ្យដាវ

សូមផ្ញើចំពោះទៅលោក ម៉ៅ-ម៉ី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ

ADRESSE: Monsieur Mao-Mey Ministère de L'Intérieur P.Penh

សេចក្ដីជូនដំណឹង

សូមព្រះថេរានុត្តរៈនិងអស់លោក - អ្នក - មិត្តទាំងឡាយ ដែលបានជាវទស្សនាវដ្ដីនេះ ហើយពុំទាន់បានបង់តម្លៃជាវនៅឡើយនោះ សូមទានមេត្តាផ្ញើបង្គ្រប់ប្រាក់ទៅបង់តម្លៃឲ្យទានដោយអនុគ្គហភាព ។ ព្រោះពលភាពនៃថវិកាសម្រាប់បំណាយបោះពុម្ពនោះ កាន់តែខ្សត់ខ្លួយណាស់ទៅហើយ ។

សូមព្រះថេរានុត្តរៈនិងអស់លោក - អ្នក - មិត្តទាំងឡាយ មេត្តាជួយឧបត្ថម្ភទំនុកបម្រុងដល់ភាពនៃទស្សនាវដ្ដីនេះឲ្យមានពលភាព-វឌ្ឍនភាពជាស្ថាពរតទៅឲ្យទានផង! ។

សូមអរគុណទុកជាមុនដ៏ជ្រាលជ្រៅដោយសេចក្ដីស្មោះស្ម័គ្រ! ។

ទិដ្ឋភាពកម្ម

ជំហានអក្សរសាស្ត្រជាតិ

គេដឹងហើយថា កាលបរិច្ចេទនៃការប្រើអក្សរសាស្ត្រជាតិតាមផ្លូវការបានកន្លងផុតមក ១ខែហើយ តើលទ្ធផលនោះចំរើនដល់ណា ?

បំពេះរឿងនេះយើងមិនចាប់ពណ្ណនាឲ្យវែងឆ្ងាយពេកនេះព្រោះគ្រប់ពាក្យសារពត៌មានខែរៀងទូទៅក៏ចានរាចទាចចំលើបញ្ហាអក្សរសាស្ត្រនេះដែរ ចាំងពីកាលវេលាមិនទាន់មកដល់ម្ល៉ះ ។ ប៉ុន្តែមត៌អ្នកអានទាំងអ្នកនិពន្ធ ដូចជាមិនទាន់រៀបចំបញ្ចូលក្នុងគ្នានៅទេ្ធយ ដោយហេតុតែជនជាតិយើងពេញចិត្តយករឿងផ្ទាល់ខ្លួនមកចោទលាយជាមួយផង ។

ដើម្បីឲ្យងាយដោះស្រាយបញ្ហាអក្សរសាស្ត្រជាតិ ត្រូវយើងយកខែរណាដែលយល់ច្បាស់ទូលំទូលាយ ជាតិ ទាំងសេចក្ដីសម្រេចនៃសមាជជាតិលើកទី១ ទាំងមត៌គណ:កម្ម ការវិវត្តធម្ម មកធ្វើជាចាន់នៃបញ្ហានោះទើបអាចដោះស្រាយបាន ។ បើសិនណាជាយើងចេះតែបណ្ណាយហើយមិនចានបន្ទឹងកងរឿងនេះទេ ល្បឿននៃអក្សរសាស្ត្រជាតិពិតជាមិនលឿនទៅមុខទេ្ធយ; ការបន្ទឹងកងដំណើរអក្សរសាស្ត្រនឹងកើតទេ្ធងចានកំ ណាស្រ័យឥស្សរ:ជនទូទៅក្នុងព្រះរាជណាចក្រ ដែលនៅក្នុងដំណែងជានាយកនៃការិយាល័យនិមួយ ។ ហើយត្រូវការចាប់ផ្ដើមប្រតិបត្ដិពីឥស្សរ:ជននោះ ។ ផង ។

ខ្ញុំតែងឮពាក្យពោលជំទាស់ដែលមិនសមហេតុផលជាច្រើនដូចជាថា «មិនទាន់មានប្រកាសចេញបង្ហាប់, ខ្ជះអត្ថ្ចលីលេខប្រ, ធ្វើការយឺតជាដើម» ពាក្យប៉ុណ្ណេះនេះក៏មិនសមនឹងឲ្យឮដល់ត្រចៀកគេងងងឹតទេ្ធយ ។ ម្ខាងវិញទៀត យើញថាខ្ជះការទម្លាប់

មួយ យ៉ាងសំខាន់គឺដូចជាការលើលិខិតសម្រាប់ចង្អាប់ទៅលើបុគ្គលិកតូចតាចកំដាយ ក៏
គង់នៅបូលចិត្តការអក្សរបរទេសដែរ ទម្ងាប់នេះមិនគួរសោះ បើយើងសរសេរគ្រាន់តែឲ្យ
ស្គាល់យើងមើលប៉ុណ្ណោះម្តេចក៏ចាំសរសេរជាអក្សរបរទេសដែរ! ? ប្រកាសក្រសួងក្តីព្រះពជ
ក្រិត្យព្រះពជក្រមក្តីដែលធ្វើឡើងជាអក្សរបរទេសក៏រតែតែការប្រើនណាស់ទៅទៀត ចុះ
ទាស់អ្វី?បើយើងគ្រាន់តែសរសេរជាអក្សរជាតិម្ចាស់ទៅមិនបានឬ?ដូចជាបទបញ្ជា ខ្លះដែល
សំរាប់ប្រើក្នុងប្រទេសយើងក៏ដាយ ក៏នៅតែធ្វើតែសរសេរអក្សរបរទេសផងដែរ ហើយបើ
គេសួរដេញដោលទៅថា អក្សរគេវាមានរបៀបបែបផែនត្រឹមត្រូវពិតប្រាកដជាងអក្ស
ជាតិយើង ខ្លះទៀតថាមើលអក្សរខ្មែរពុំសូវយល់ទេ បើមើលអក្សរបរទេសវិញនោះទើប
បានយល់,, ? ពាក្យនេះសូមខ្មែរកុំបបួលគ្នានិយាយឲ្យសោះ បើជាតិដទៃគេពូមុខតែ
សើចទឹងយើងរយះមាត់មិនទានទ្រាយ; មិនដែលមានបើខ្លួនជាខ្មែរហើយស្អាប់ខ្មែរមិន
យល់នោះ ចុះឲ្យជាតិណាទៅវិញគេយល់ខ្មែរជាងខ្មែរយើងបាន ?

អើយើងគួរដឹងខ្លួនខ្លះទៅថា បើខ្មែរមិនព្រមរៀនខ្មែរមិនព្រមយល់ខ្មែរ តើទុកឲ្យ
នរណាគេរៀនខ្មែរហើយយល់ខ្មែរដំនួសខ្មែរទៅវិញ រឿងនេះគេមុខតែគេបានយើងថា
ជាន់ខ្មែរពន្ធិបទៅកគ្រោះគ្រាទៀតហើយ ?

ឋណ្ណាធិការ

សំណៀងសាសនា

(ក)

លោក-អ្នក បព្វជិតគ្រហស្ថទាំងឡាយ !

កាលព.ស. ២៤៩៧ គ.ស. ១៩៤៣ កន្លងទៅហើយ ជាកាលកំណើតរោគ ដែលចាប់កើតជាលើកដំបូងក្នុងការផ្ទុកកាយរបស់ខ្ញុំកុណ្ណា អាត្មា សំដែងអាការកំណៀវ ហួសហេតុ ចាប់ផ្តើមចាកចេញពីដូចអាសិរពិស ចាប់ឈឺពីតចាក់ រុកពេលដាលក្នុងអង្គកាយនេះស្ទើរតែអត់ទ្រាំពុំបាន តែដោយអំណាចតេជានុភាពសម្តេចព្រះមហាក្សត្រយាន មានព្រះសុវណ្ណ បញ្ជាឲ្យលោកគ្រូពេទ្យនាម អេម មកព្យាបាលជាលើកដំបូង ប្រចាំងទប់ទល់នឹងរោគនេះជាពាល់ថ្ងៃ, បន្ទាប់មកបានយកលោកគ្រូពេទ្យ (Docteur) ផ្ទាស្ស៊ី មកប្រយុទ្ធនឹងរោគនេះទៀតក៏បានជាសស្បើយគ្រាន់បើហួតមកដល់ ព.ស. ២៤៩៩គ.ស. ១៩៥៦, រោគនេះក៏ស្ទើរជាថ្មីឡើងវិញ ក៏បានយកលោកគ្រូពេទ្យ (Docteur) ជ្ជួន-ដ្ជឿន នឹងលោក លាន-ស៊ាន មកព្យាបាលប្រយុទ្ធនឹងរោគដដែលនេះថែមទៀត ទាល់តែរោគនេះសាបវិលាបបាត់ទៅ នាំឲ្យខ្ញុំកុណ្ណា អាត្មា មានខ្យល់អស្ចារ្យសប្ប្ស្ចារ្យសដើរធ្ងន់ស្រាលឡើងជាដរាប ។

ឧកាសនេះអស់លោក-អ្នកដែលជាក្រុមបព្វជិត ឧបាស-ឧបិកា ទាំងឡាយ ដែលមានសេចក្តីស្នេហាចំពោះខ្ញុំកុណ្ណា អាត្មា បានមូលមតិស្រមគ្នា ធ្វើបុណ្យកតញ្ញូជាកុសលដើម្បីតបបដិការគុណ ឧទ្ទិសប្រគេនចំពោះខ្ញុំកុណ្ណា អាត្មា ។ មានសេចក្តីត្រេកអរជា

ភ័យរ្យាភាព ហើយបានតាំងសតិធ្វើមនសិការៈប្រកបដោយមានសញ្ញតនា ធ្វើបដិគ្គ
ហណកិច្ចទទួលយកកុសលនេះ ដែលជាឧបការគុណដ៏ប៉ិសុទ្ធរបស់អស់លោក-អ្នក
ដែលបានប្រសិទ្ធជាបុញ្ញប្ការប្រកបដោយសោមនស្សជ្រះថ្លា ប្រគេនចំពោះខ្ញុំកុណ្ណា
ត្ថា សូមកុសលនេះឧបត្ថម្ភជួយជាកម្លាំងបណ្តាញ្ញាណគាពធ ដែលមានក្នុងអត្តភាយ
របស់ខ្ញុំកុណ្ណា អាត្ម្ន ឲ្យរលាយបាត់ខ្ចាត់ខ្ចាយចេញពីសរីរៈ តាំងពីថ្ងៃនេះតរៀងទៅ
ដោយអំណាចបុណ្យកតញ្ញូតាបរបស់អស់លោក-អ្នក ដែលបានប្រសិទ្ធដោយសុទ្ធបិត្តដ៏
ស្អាតប្រគេនចំពោះខ្ញុំកុណ្ណា អាត្ម្ន ។ បានធ្វើអាយាចនវ៉ាចាបួងសួងដោយស័ក្តិសិទ្ធិនេះ
សូមឲ្យសម្រេចសេចក្តីប្រាថ្នាជាទាងក្រោយបង្ហើយកិច្ចបុណ្យកតញ្ញូតាតែប៉ុណ្ណោះ ។

បន្ទាប់អំពីនេះទៅ ខ្ញុំកុណ្ណា អាត្ម្ន សូមលើកកុសលដែលកើតអំពីបុណ្យកតញ្ញូ
តាបរបស់អស់លោក-អ្នក ដែលបានប្រគេន ខ្ញុំកុណ្ណា អាត្ម្ននេះ ហ្វាយជាព្រះពរជ័យចំពោះ
ព្រះកុណ្ណាជាម្ចាស់ជីវិត, សម្តេចព្រះមហាក្សត្រិយានី, សម្តេចព្រះឧបយុវរាជ សូមទ្រង់
ស្ថិតនៅក្នុងសីរីពរជសម្ផត្តិ ប្រកបដោយសុខសួស្តីជ័យមង្គលគ្រប់ប្រការអស់កាលជា
អង្វែងតទៅ ។

សូមឧទ្ទិសភាគផលនេះ ជូនចំពោះទេវបុត្រ ទេវតា មារ ព្រហ្ម យមយក្ស អារ្ម
ណ៍ ទេព្រ៍ក្ស ទ័ងមនុស្សទាំងឡាយ ព្រមទាំងសត្វទ្ទេចាទ ចតុប្ផាទ ពហុប្ផាទ
សូមទទួលយកដោយសញ្ញា ហើយសូមឲ្យមានអាយុយឺនយូរអស់កាលដ៏ឡូង ។

សូមឧទ្ទិសភាគផលនេះ ជូនចំពោះក្រុមសិស្សានុសិស្សបព្វជិតគ្រហស្ថ ឧបាសក
សិការទាំងឡាយ ដែលជាអ្នកឧស្សាហ៍ធ្វើបុណ្យកតញ្ញូតាផ្ទាល់ខ្លួនជូនចំពោះខ្ញុំកុណ្ណា
អាត្ម្ន ដែលជាគ្រូបានធ្យាយរបស់អស់លោក-អ្នក សូមលោកអ្នកទាំងនេះបានមូលមិត្តមូល

សំឡាញ់ មូលក្រុមគ្រួសារ កុំឲ្យបែកបាក់ចាកគ្នា កុំឲ្យមានរោគាទាំងពួងបៀតបៀន ប្រាសចាកទុក្ខភ័យទុប្ទ្រពចង្រៃគ្រប់យ៉ាង សូមឲ្យបានប្រកបដោយសេចក្ដីសុខចំរើន មានទីឃាយុយឺនយូរ ទាំងសូមឲ្យមានសាមគ្គីរសស្មោះសរគ្នា កុំឲ្យមានពៀរវេរានឹងគ្នាអស់កាលជានិរន្តរ៍ប្ដូរចំរើនក្នុងព្រះពុទ្ធសាសនាតរៀងទៅកុំបីឃ្លាតឡើយ ។

ទីបំផុតនៃសំរេតប្រកាសរបស់សម្ដេចនេះ ខ្ញុំព្រះករុណាអាត្មាភាពសូមបួងសួងដោយមេត្តាករុណាចិត្ត ចំពោះសម្ដេចផង ចំពោះពុទ្ធបរិស័ទ្ធទាំងអស់ផង ជាគាថាបាលីដោយសង្ខេបថា.

អម្ហាកំ សម្ដេចព្រះធម្មលិខិត ឧត្តមប្រឹក្សា មហាបរិវស្ស រោគាតក្ក នានាពាធគិលានាយ វិហេឋយន្តា អម្ហាកំ កតញ្ញូតានុភាវេន ឥតោ បន្លាយ មា អហេសុំ វិនស្សន្តុ អសេសតោ ។

ពុទ្ធវិជ្ជា នាម អហម្បន សព្វស្មឹ លង្កាវាមេ វិសន្តានំ ភិក្ខុសាមណេរានំ ឧបាសកឧបាសិកានញ្ច សាមគ្គីករណតាយ និទំ វិបនមព្រឹ, សព្វេ តុម្ហេ មហាបុញ្ញា មហាបញ្ញា មហព្វលា មហាភោគា មហាយសា មហានុភាវា សព្វធម្មេសុ ចិតា សព្វធរាពុទ្ធសាសនមាមកា សីលវន្តោ ជិនានម្បិយា សមគ្គា ហោថ សព្វេតុម្ហេ អញ្ញមញ្ញាវិរោធិនោ, និទំ សព្វំ លង្កាវាមំ នាម ឋានំ អញ្ញំ អនុំ ឯវំ មា វីសុំ ហោតុ មេត្តាយោគ្គេកសម្ពន្ធំ សុខំ បវត្តំ ។

តេ តេ ភិក្ខុសាមណេរានុយោ អវិវាទា អវិកលហា អភិន្នា

សម្មា សមគ្គា សាធុកំ សម្បដិបិន្នា ពុទ្ធសាសនំ ធម្មវិនយសម្បន្នំ វុឌ្ឍិ ចិរំ តិដ្ឋតុ សកសកអាវាសេសុ ច សកសកបរិយត្តិយា ច សកសកគេហង្គណេសុ ច សុវត្ថិភាវេន សព្វទា (១) ។

នាកាលសុន្ទរកថារបស់លោកសាស្ត្រាចារ្យឈឹម-ស៊ុម ទីនសង្កេតប្រកាសរបស់ព្រះតេជព្រះគុណព្រះពុទ្ធវង្សចប់ហើយ, ព្រះមហាថេរទាំង១០អង្គ ក៏ចាប់ស្វាធ្យាយធម៌ជយន្តោទីនធម៌ជាពរឯទៀតខ្លះទៀត ជាកិច្ចប្រសិទ្ធិអាយុវឌ្ឍនមង្គលប្រគេនចំពោះសម្តេច ។ ជាបន្ទាប់នោះ, សម្តេចព្រះមហាសុមេធាធិបតី, កនចំណោមព្រះថេរទាំង១០អង្គ,បានបួនសួនសូមឲ្យសម្តេចព្រះធម្មលិខិតសះស្បើយចាករោគាពាធជាលំដាប់តាំងពីពេលនេះទៅ ដើម្បីបានជាម្លប់ទីនជាទីគោរពរបស់ពុទ្ធសាសនិកទាំងឡាយ, ព្រះពុទ្ធដីកាសម្តេចជ្រៅទៅទៀតថា “យើងមិនអន្ទះទេ ចំពោះអាការរោគព្រោះយើងបានដឹងថា រូបកាយសព្វសត្វសុទ្ធសឹងតែជាសម្បុករោគ សុទ្ធតែបែកធ្លាយទៅវិញជាធម្មតាហើយ យើងមិនអន្ទះទេចំពោះអាការរោគ ព្រោះយើងដឹងថា រូបកាយសត្វទួទៅសុទ្ធតែជាលំនៅរោគ សុទ្ធតែបែកធ្លាយទៅវិញជាធម្មតា ប៉ុន្តែយើងសូមអរចំពោះគុណធម៌ប៉ុណ្ណោះ ដើម្បីឲ្យជួយកំចាត់រោគាពាធ ហើយជួយទ្រទ្រង់សម្តេចឲ្យមានកម្លាំងពលំតទៅទៀត ។ ឯព្រះតេជព្រះគុណព្រះពោធិវង្ស ក៏បានបួនសួនសូមឲ្យសម្តេចមានព្រះកាយពលឡើងវិញដែរ ដើម្បីនឹងជួយទ្រព្រះពុទ្ធសាសនាទៅអនាគតទៀត ។

(នៅមានត)

១– សង្កេតប្រកាស ដែលព្រះតេជព្រះគុណព្រះពុទ្ធវង្សរចនាឡើងនេះដោយគណៈកម្មការវត្តលង្កា តម្រូវឲ្យធ្វើតាមសមគួរដល់ការសូត្រជាតំណាងសម្តេច ទទួលអំណរចំពោះសិស្សគណទាំងអស់ ក្នុងពេលធ្វើបុណ្យកតញ្ញូ ។

ស្ថានការណ៍នៃសហភាពភូមា(តនិងចប់)

បំណែកស្ត្រីបង្រៀនឲ្យចេះត្បាញ ចេះរវៃ ដេរប៉ាក់ ប៉ាស់ប៉ុនបំណះដាច់ដាច បាន ដូចគ្នានឹងស្ត្រីអ្នកជា ហើយគ្រាន់បើជាជាងស្ត្រីអ្នកជា ដែលល្ងង់ខ្ជិលច្រអូសពុំប្រកប ការងារផ្សេងៗ ។ បំណែកខាងបុរស បង្រៀនឲ្យចេះអានសរសេរអក្សរ ឬក៏ត្បាញល្អី អង្រឹងជាដើម ប្រហែលគ្នានឹងបុរសដែលអ្នកជា តែគ្រាន់បើជាបុរសអ្នកជាល្ងង់ខ្លៅ ខ្ជិលច្រអូស ពុំបានរវាសរវៃប្រកបកិច្ចការផ្សេងៗទៅទៀត ។ គួរបើដែរ បុរសស្ត្រី ដែលអន្ធការ ភ្នែកខ្វាក់សោះ រដ្ឋាភិបាលគេចេះតែខំឲ្យបានការទៅជាមនុស្សមានប្រ-យោជន៍ មានការងារធ្វើប្រហែលគ្នានឹងមនុស្សសាមញ្ញដែរ ។ ដូច្នេះគួរគិតថា កិច្ចការក្នុងលោកមិនហួសវិស័យនៃមនុស្សក្នុងលោកទេ គ្មានអ្វីឲ្យកែជាជាងសេចក្តីព្យា-យាមធ្វើ ព្យាយាមគិត-សន្សំត្រិះរិះពិចារណានោះទេ ។

១ទៀត គេមានបង្កើតសមាគមការអប់រំសីលធម៌អារ្យធម៌ ដល់ពួកកុមារ-កុមារីទាំងឡាយ គឺបង្ហាត់បង្រៀនកុមារនឹងកុមារី ឲ្យចេះថ្លែងការណ៍ទូន្មានប្រៀនប្រដៅ នឹងដាស់តឿនក្រើនរំឭកគ្នា ដោយពាក្យជាអាទិ៍ថា ហៃកុមារទាំងឡាយ! យើងជាកុមារពិត តែយើងជាពលរដ្ឋនៃប្រទេសដែរ, យើងត្រូវនាំគ្នាសិក្សាបំណេះវិជ្ជា-ផ្សេងៗតាំងខ្លួននៅក្មេង, យើងត្រូវពួតដៃគ្នាកសាងជាតិ មាតុប្រទេស, អំណើះអំពីបិតាយើងទៅ យើងហ្នឹងឯងហើយជាបង្គោលនៃប្រទេស, នាំគ្នាការពារសត្រូវដែលប៉ងបៀតបៀនយើង, យើងត្រូវរក្សាសាមគ្គីរវាងជាតិយើង! ដូច្នេះជាដើម ។ បំណែកកុមារីក៏មានការអប់រំយ៉ាងនេះដែរ ម៉្លោះហើយកុមារ-កុមារីទាំងឡាយ ឃើញឮដឹងជាក់នូវស្ថានការណ៍បែបនេះហើយ យូរៗទៅគង់ភ្ញាក់ស្មារតី ប្រែគំនិតប្រាជ្ញា

លះបង់នូវអំពើឃោរឃៅ កំទិតរបុលរបួចវិលខូចបន្តិចម្តងៗ ដោយសារជម្រាននគ្នាៗ សម្បូលគ្នាខ្លះ អំពីសំណាក់គ្រូអាចារ្យខ្លះ អំពីបិតាមាតាខ្លះ អស់ទយកាលយ៉ាងនេះ គង់ក្លាយទៅជាមនុស្សត្រឹមត្រូវ មនុស្សបានការពុំខាន ទាំងជាហេតុនាំឲ្យបំរើន សតិបញ្ញា នឹងមានសមត្ថភាព សេចក្តីក្លាហាន ការថ្ងៃថ្ងៃថែមទៀតផង ។

១៣– អំពីរថយន្តៈ– រថយន្តទាំងឡាយ ទោះបីតូចក្តីធំក្តី ដែលបើកបរក្នុងទីក្រុងក្តី-ខែត្រ-ស្រុក-ឃុំ-ភូមិ គេប្រើនប្រយ័ត្នប្រយ៉ែងណាស់ ទីណាដែលកុះករដោយមនុស្សម្នាមហាជន គេបើកតិច បន្លឺនស្នូរមិនឲ្យសៀនហួសប្រមាណទេ ពីព្រោះគេការពារដល់គ្រោះអន្តរាយផ្សេងៗ ទាំងមិនដាក់ផ្ទុកអីវ៉ាន់លើដំបូលរថយន្តឲ្យហួសបំណុះទេ តាមការពិត គេមិនឲ្យផ្ទុកអីវ៉ាន់លើដំបូលរថយន្តផង ។ អ្នកដែលធ្វើដំណើរតាមរថយន្ត មានការទៅមកដោយស្រួល ទាំងអ្នកម្ចាស់រថយន្តទាំងឡាយប្រើអាការៈល្អ សំដីទន់ភ្លន់ទៅរកអ្នកដំណើរ មិនប្រើសំដីគំហ៊កគំហល់គំហែងសោះឡើយ ។ ទាំងកុបាល់ឬកាណូតក៏ដូចគ្នា គេមានការថែទាំស្អាតបាតជានិច្ច ហាមមិនឲ្យយកក្រណាត់សំពត់ដាប់ដាច ឬបំណែកបាវគណ្តាប់គណ្តាចយកទៅបិទបាំងក៏ដៅថ្ងៃឡើយ ព្រោះគេយល់ថាកិច្ចការទាំងនេះតូចតាចពិតមែន តែបើពជការបណ្តែតបណ្តោយការនេះជាហេតុនាំឲ្យខូចដំនៀ ខូចកិត្តិយសរំលប់ប្រទេសពិត ព្រោះហេតុនោះ អ្នកពជការទាំងឡាយហាមប្រាមអ្នកម្ចាស់កុបាល-កាណូត មិនឲ្យធ្វើការខ្ជីខ្ជាយកតែមានសំពត់រដាប់រដោបទៅបិទបាំងទេ ។ បើគ្មានការបង្គាប់បញ្ជាយ៉ាងនេះ កាលបើអ្នកទេសចរពីប្រទេសក្រៅ ធ្វើដំណើរគ្រាប់ទៅមកពីប្រទេសមួយទៅប្រទេសមួយ គេអាចតិះដៀលបាន ព្រោះខ្វះសីលធម៌ខាងការស្អាតបាត ។ នៅគេស្ថាន

តាមវិថីតូច-ធំទៀតផង គេមិនឲ្យហាលវត្ថុមានសំពត់អាវជាដើមនៅលើវណាន់ទេ គឺត្រូវមានកន្លែងសម្រាប់ហាលដោយឡែក មានរបៀបរៀបរយនគួរល្អមើលគួរជាទីទស្សនាការ ។

នៅប្រទេសខ្មែរយើង សម័យមុនពួកថៅកែ កុម្ពុល កាណូត នឹងទាវតូចធំទាំងឡាយ មានការថែទាំនាវរបស់ខ្លួនដោយត្រឹមត្រូវល្អ ទាំងមិនបណ្តែតបណ្តោយឲ្យពួកកម្មករ ធ្វើការតាមមានតាមបានឡើយ ។ លុះដល់ជំនាន់ស្រុកក្រ ក្រណាត់ឡើងថ្លៃគ្រប់នាវទាំងឡាយ ដែលបើកបរតាមទន្លេ ស្ទឹង យកក្រណាត់សំពត់ជាប់ជាបនឹងក្រណាត់បាវរជាប់ដោចទៅបិទបាំងកំដៅថ្ងៃជានិច្ចនិរន្តរ៍ តែដល់ស្រុកសម្បូរសប្បាយ អំពើដែលធ្វើដោយខ្ជិលខ្ជានោះៗ នៅជឹតជាប់រហូតដល់សព្វថ្ងៃ គេពុំបានផ្លាស់ប្តូរទៅតាមកាលៈទេសៈសោះឡើយ ។ ទាំងទង់ជ័យ ដែលត្រូវដោតបង្ហើរលើនាវទាំងឡាយទៀតផង ខ្លះដោតឲ្យតែមានបាន ខ្លះគួរអាសឲ្យខាងតែបាន អ្នកផងមើលទៅ ពុំឃើញប្រាកដថា ទង់ជ័យដែលគេដោតលើនាវទាំងនោះ ជាទង់ជ័យប្រចាំប្រទេសណា មានសណ្ឋានទ្រង់ទ្រាយដូចម្តេច មានវិចិត្រដោយរូបភាពអ្វីខ្លះទេ

ព្រោះហេតុនោះ នៅគ្រប់ប្រទេសទាំងឡាយ ដែលស្ថិតនៅជិតខាងប្រទេសយើងគេប្រយ័ត្នណាស់ មិនឲ្យធ្វើខ្ជិលខ្ជាទេទាំងអក្សរដែលសរសេរដាក់ឈ្មោះម្ចាស់ផ្ទះ នៅគ្រប់ផ្លូវគ្រប់ច្រកល្ហកទៀតផង ក៏គេចាត់ការឲ្យសរសេរដាក់ឲ្យត្រឹមត្រូវផងដែរ គេឲ្យមានផ្លាំងក្តារ ឬផ្លាំងបង្កស៊ីតូចធំប៉ុនគ្នា ស្នាមគំនូសអក្សរប៉ុនៗគ្នា ខ្ពស់ទាបដូចគ្នាទាំងអស់, នៅផ្លូវណាប្រើអក្សរធំ កធំទាំងអស់, ផ្លូវណាប្រើអក្សរកណ្តាលៗទាំងអស់ ផ្លូវណាតូចល្មមៗទាំងអស់, អ្នកផងមើលទៅអំពីចម្ងាយរត់របត់ផ្លូវ មិនទើសភ្នែកឡើយ ។

១៤៖ អំពីគ្រឿងបរិភោគ អាហារនៅសហភាពភូមាស្រដៀងគ្នានឹងអាហារនៅប្រទេសខ្មែរដែរ (តែអង្ករប្រើនទន់ ចំអិនអាហារទទួលទានស្រួល) ដែលម្ហូបគ្នានោះគឺ សម្ល នឹងបង្អែមខ្លះ ៗ តាមធម្មតា នៅប្រទេសខ្មែរយើង និយមប្រើខ្ទាញ់សម្រាប់បង់ហោយជាមួយ សាច់ម្ហូបនៃផ្សេង ៗ ទាំងបង្អែមខ្លះ ៗ ក៏និយមប្រើខ្ទាញ់ដែរ ៗ តែនៅសហភាពភូមា ប្រជាជនទូទៅនិយមប្រើប្រេងដូង ឬប្រេងសណ្តែក សម្រាប់បង់លាយជាមួយសម្ល ឬបង្អែមគ្រប់យ៉ាង ។ ឯទឹកគ្រឿងខ្ទុសពីប្រទេសយើង ទឹកគ្រឿងសម្រាប់ជ្រលក់ផ្ទាប់ជាមួយបន្ទៃគ្មានទឹកទេ គ្រាន់តែផ្ទាប់ជាមួយបន្ទៃជាការស្រេច ។ ឯគ្រឿងផ្ទាប់នោះ ១ ធ្វើពីកម្ទិសតូច ១ គេហៅថា ត្រូវគ្នានឹងភាសាយើងថា «ការ៉ី» គេបុកម្ទេះជាក់លាយជាមួយគ្នាផង ។

បង្អែម ១ ប្រភេទដែលយើងពុំធ្លាប់ដែលធ្វើ, រាងប្រៀបធ្វើប្រហែលគ្នានឹងចេកចៀនដែរ តែនៅប្រទេសយើង ប្រើនដាក់ចេកធ្វើជាស្ពៃ ។ ឯប្រទេសគេ ចេកចៀនក៏មានដែរ តែមានបង្អែម ១ ប្រភេទទៀត ហៅថាត្រឡាចចៀន គេចិតត្រឡាចជាចំណិតតូច ១ ជាក់ចំតណ្តាល រាងប្រៀបចៀនដូចគ្នាចេកចៀនមានជាក់ប្រេងនឹងមេម្ស៉ាលាយលៃ ១ ដូចគ្នា រៀលទទួលទានគេផ្ទាប់ជាមួយនឹងស្ករកន្ទៃ សាលាដ៏ ខាត់ណា នឹងដំរដ្ឋ ១ ព្រមទាំងទឹកគ្រឿងផង ។ គួរតែធ្វើទទួលទានសាកលមើលកុំខានបើឃើញថាស្រួលគប្បីធ្វើឲ្យប្រើនតាមគាប់ចិត្ត ។

១ ប្រភេទទៀត គេហៅថា « កម្ទិសចៀន » រាងប្រៀបចៀនដូចគ្នានឹងត្រឡាចចៀនដែរ ដំបូងគេដាក់ប្រេងទៅក្នុងខ្ទះ ១ ដាក់មេម្ស៉ាពេយបន្តិច ១ ពីលើ ហើយគេពាយកម្ទិសនៅពីលើថែមទៀត តែកុំដាក់មេម្ស៉ាប្រើនពេក គេដាក់កម្ទិសប្រើន

ផាន ពេលទទួលទាន ត្រូវផ្សំគ្រឿងទឹងបន្ថែ ទឹកជ្រលក់ដូចគ្នានឹងត្រឡាបបៀនដែរ ។ របៀបនេះ គួរធ្វើទទួលទានសាកមើលដែរ បើឃើញថាឆ្ងាញ់ពិសា ចូរធ្វើឲ្យញយ ៗ ទៅ ។

១៥– របបពិសេស៖ ប្រជាជនកម្ពុជា ពួកជនអ្នកទីទ័លក្រគេពុំដែលឃើញ ទៅប្រកបការងារជាទាសកម្មករ លីសែងរែកពុនឲ្យជនជាតិដទៃ ដូចជាជាតិចិន ហិណ្ឌូ ឥណ្ឌូនេ ខុសគ្នាពីប្រជាជនខ្មែរនៅប្រទេសខ្មែរ នៅតាមក្រុង-ខេត្ត-ស្រុកភូមិឃុំតាមផ្លូវផ្សារ គេតែងជួបប្រទះប្រជាជនជាតិខ្មែរអ្នកទីទ័លក្រ សែង លី ពុន រែក អីវ៉ាណឲ្យជនជាតិចិនជាញឹកញាប់ណាស់ ។ ឯប្រជាជនកម្ពុជាប្រកាន់ខ្លួនជាដាច់ខាតចំពោះអំពើនេះ បើជាខ្លួនក្រីក្រ សុំយកខ្លួនទៅធ្វើជាកូលីរាជការខ្ញុំរាជការ សុំប្រាក់ខែរាជការ មិនឲ្យជាតិដទៃ ប្រើខ្លួនជំនួសសត្វពាហណៈ ដូចជាក្របីគោ សេះដំរីទេ ទាំងជាហេតុនាំឲ្យថោកសញ្ជាតិផង ។

១ទៀត អស់រយៈកាលដ៏យូរមកហើយ គេពុំដែលឃើញរដ្ឋាភិបាលកម្ពុជា ចាត់ចូលិសឲ្យស្ពាយកាំភ្លើងបណ្ដើរពួកចោរដើរកាត់ផ្លូវផ្សារទៅធ្វើការងារផ្សេង ៗ ទេគេឃាំងទុកក្នុងពន្ធនាគារ ឲ្យធ្វើការងារផ្សេង ៗ តាមមុខការដែលត្រូវធ្វើក្នុងពន្ធនាគារៗ ការធ្វើយ៉ាងនេះ ដើម្បីបំបាត់ចោលនូវអំពើឃោឃៅ ការស្អប់ស្អែងនៃអ្នកជនដទៃ ។ល។...

(១៥)៖ យោបល់ពិសេស៖ អំពីរស្មីនៃឯករាជ្យ នៅប្រទេសកម្ពុជាយើង មានព្រះមហាក្សត្រជាប្រមុខ ជាទីគោរពនៃពលរដ្ឋខ្មែរទូទៅទាំងប្រទេស, តាំងពីបុរាណសម័យរៀងរាបដរាបដល់បច្ចុប្បន្នសម័យ ប្រជាជនខ្មែរទាំងសកលតែងមានការរំភាពនឹងស្វាមី

ភក្តីដ៏ជ្រាលជ្រៅចំពោះព្រះមហាក្សត្រ ប្រចាំប្រទេសរបស់ខ្លួនយ៉ាងស្មោះស្ម័គ្រ ទុកដូចជាសរណវត្ថុ ដែលជាទីស្រឡាញ់ ជាទីគោរពបូជាដែរ ។ ប្រទេសដែលមានព្រះមហាក្សត្រទ្រង់រាជ្យ ទុកដូចជាមហាប្រាសាទប្រដាប់ដោយកំពូល ឬដូចជាគ្រឹះស្ថាននឹងវិមានដែលមានសសរស្តម្ភដែរ ។

បុរាណសម័យ ប្រទេសខ្មែរយើង មានពន្លឺរស្មីរុងរឿងក្រៃពេក ហាក់ដូចជាព្រះច័ន្ទពេញវង់ នាតិត្ថិទី១៥កើតមានកិត្តិស័ព្ទល្បីល្បាញពាសពេញសកលលោក ប្រទេសជិតខាងកោតសរសើរស្ញើចថ្ងៃដ៏បំណាននៃបុព្វបុរសខ្មែរយ៉ាងមហាស្ចារ្យ ។ ពលរដ្ឋខ្មែរទាំងអស់សប្បាយរីករាយយ៉ាងក្រៃលែង ឥតមានព្រួយបារម្ភអ្វីឡើយ ព្រោះគ្មានសត្រូវនោះខាងក្នុងប្រទេស ខាងក្រៅប្រទេសក្តី ក៏ប្រកបដោយសន្តិសុខសន្តិភាពដូចគ្នា រដ្ឋាភិបាលមានសិទ្ធិនឹងសេរីភាពពាត់ការកាន់ប្រទេសបានដោយសេរី ។ លុះកន្លងមករាប់៨០ឆ្នាំប្លាយប៉ុណ្ណោះ ប្រទេសខ្មែរយើងដុនដាបធ្លាក់ទៅនៅក្នុងកណ្ដាប់ដៃនៃពួកជនបរទេស កិច្ចការគ្រប់យ៉ាងនៅលើកណ្ដាប់ដៃនៃជនបរទេសទាំងស្រុង អសន្តិសុខកើតពាសពេញនៃផ្ទៃប្រទេស ប្រជាជនខ្មែរបាត់សាមគ្គីភាពរវាងជនមានសញ្ជាតិដូចគ្នាអស់ ថែមទាំងកើតទុក្ខទោរម្នេញពល់ទិវារាត្រី គ្មានបុគ្គលរូបណា មានគំនិតខ្វែងវែងអង់អាចមានសមត្ថភាព នឹងប្រតិពលព្រមទាំងប្រាជ្ញាឈ្លាសអាចត្រិះរិះពិចារណាឃើញជ្រុះជ្រាយ ឬមាន១បាយដ៏ក្លាហានកាប់គ្រាយក្តារនូវអំពើឃោរឃៅ អំពើយង់ឃ្នង ការរើបជាន់ ការសង្កត់សង្កិនដោយពលក្ការអំពីសំណាក់ពួកជនបរទេសបានឡើយ ពោះបីអ្នកនោះមានសមត្ថភាពបែបណាក៏ដោយ ពីព្រោះពួកជនជាពលរដ្ឋខ្មែរគ្រប់រូបមានសម្បទាពុំគ្រប់គ្រាន់ប្រើនតែគិតត្រឹមតែប្រយោជន៍ផ្ទាល់ ។ ខ្លួនមួយ ឬក្រុមគ្រួសារ

១ក្រុម ៗ ប៉ុណ្ណោះ មើលពុំឃើញឆ្ងាយ ស្ដាប់ជិត ៗ ផ្តល់ប្រយោជន៍ពុំបានទៅទាំងប្រទេស ៗ

សម័យបច្ចុប្បន្ននេះ ប្រទេសកម្ពុជា មានមហាក្សត្រជាប្រធាន ជាទីតាំង ហាក់ដូចជាប្រសាទពេជយន្តដែលមានកំពូលជាទីតាំង មានផ្កាហ្វូកាញ្ញគ្រឿងអលង្ការ មានក្បូរក្បាច់របនាជាគ្រឿងលំអរ មានសម្ដេចព្រះឧបយុវរាជជានាយចង្ក្រត នឹងជាមគ្គុទ្ទេសក៍ព្រោះព្រះអង្គមានព្រះបញ្ញាដ៏មោះមុត មានសមត្ថភាពដ៏ក្លាហាន មានមធុរវាចាដ៏ពិរោះពិសាគួរជាទីចាប់ចិត្តនៃពលរដ្ឋខ្មែរទូរទៅទាំងប្រទេស សូម្បីព្រះអង្គធ្វើដំណើរទៅកាន់ប្រទេសណាទោះជិតក្ដីឆ្ងាយក្ដី ពួកជនក្នុងប្រទេសនោះ តែងគោតស៊ើបសរសើរបុកពារនឹងសេចក្ដីថ្លៃថ្នូរ ប្រាជ្ញាបារមីព្រះអង្គស្មើរតែគ្រប់រូប ព្រោះហេតុនោះ ក្នុងពេលទុតិយសន្និបាតនៃផ្ដួសង្គាយនា ព្រះអង្គទ្រង់ធ្វើព្រះរាជដំណើរទៅទស្សនាការ ស្ពានការនៅក្រុងរង្គូនសហភាពភូមា ពេលនោះពលរដ្ឋសហភាពភូមា ទាំងមន្ត្រីទាំងរាស្ត្រទាំងចាស់ទាំងក្មេង តែងមានសោមនស្សចេតនា នឹងស្វាមីភក្ដិចំពោះព្រះអង្គរហូតដល់សព្វថ្ងៃនេះ ៗ មួយទៀតពលរដ្ឋខ្មែរគួរតាំងទុកថា ព្រះអង្គជាបរមក្សត្រមួយព្រះអង្គមានសញ្ជាតិជាក្សត្រជាប់ទាក់ទងមកតាំងពីសម័យអង្គវត្ត ក្នុងវង្សវរខ្មែរដោយពិត ព្រោះទ្រង់មានព្រាកដយោបល់វែងឆ្ងាយ យល់ប្រយោជន៍ដល់ជាតិសាសនាដ៏ជាក់ស្ដែង ៗ បើទុកជាទ្រង់ពុំទទួលគ្រឿងរាជសម្បត្តិក្ដី ពុំទ្រង់ទទួលចាត់វិធានការណ៍ផ្សេងៗដើម្បីប្រទេសជាតិក្ដី ក៏ព្រះអង្គឥតលំបាក ឥតនឿយព្រួយព្រះអង្គឡើយ ទាំងឥតមានបុគ្គលរូបណាស្អប់ខ្ពើម ឬរិះគន់មើលបំណាំប្រឆាំងរាសនាបារមីព្រះអង្គបានឡើយ គង់តែក្លាយទៅជាឧត្តមបុរស១រូបដ៏វិសេសវិសាលជាងបុរសទាំងឡាយ ដែលមានសញ្ជាតិជាខ្មែរដែរ ៗ

ចុះហេតុដូចម្ដេច បានជាទ្រង់ធ្វើឲ្យលំបាកព្រះអង្គ ទាំងជាហេតុនាំឲ្យប្រជាជនខ្មែរខ្លះៗ ពុំបានគិតវែងឆ្ងាយ ពុំយល់ប្រយោជន៍សាធារណៈ តិះដៀលបង្អាប់បន្ទុះពោលលើកទោស ការពិតទៅជាមិនពិត ការមែនទៅជាមិនមែនទៅវិញ ?

ឆ្លើយថា— ព្រោះព្រះអង្គមានព្រះរាជហឫទ័យស្លូតត្រង់ មានព្រះបញ្ញាដ៏ភ្លឺស្វាង មានសមត្ថភាពដ៏ក្លាហាន មានព្រះរាជតម្រិះត្រូវ យល់ប្រយោជន៍សាធារណៈទ្រង់ពុំស្ដាយស្រណោះដល់អាយុសង្ខារ ព្រោះទ្រង់មានស្នេហ៍ក្រៃបំពោះប្រទេសជាតិ បំពោះពលរដ្ឋខ្មែរ ទ្រង់ខំតស៊ូទាមទារឯករាជ្យសិទ្ធិសេរីភាពគ្រប់យ៉ាង ជូនបំពោះពលរដ្ឋខ្មែរព្រមទាំងប្រកាសឃោសនា ដាស់តឿនក្រើនរំឭកដល់ពលរដ្ឋទាំងអស់ក្នុងព្រះរាជអាណាចក្រ ឲ្យជួយជ្រោមជ្រែងកសាងជាតិ សាសនាជាមួយព្រះអង្គ ឲ្យធ្វើការដើម្បីជាតិមាតុប្រទេស ស៊ូស្លាប់ជាមួយទឹកដីជាតិដូច្នេះជាដើម ព្រះសូរសីហនាទនេះហើយដែលល្បីល្បាញខ្ទរខ្ទារគ្រប់ទិសានុទិសក្នុងពិភពលោក ។ បើទុកជាមានឧបសគ្គយ៉ាងក៏ដោយក៏ទ្រង់ពុំរួញរា ពុំកោតញញើត មិនសុខចិត្តចុះចាញ់ មានតែលឿនទៅមុខតែម្យ៉ាងដូច្នេះពលរដ្ឋខ្មែរទាំងឡាយ ទាំងគ្រហស្ថទាំងបព្វជិត ទាំងចាស់ក្មេងគ្រប់ជំនាន់ គ្រប់ឋានៈគ្រប់ថ្នាក់គ្រប់ជាន់គួរកុំព្រងើយកន្តើយ កុំមើលងាយ កុំចាំតែថ្កោលទោស កុំរំលងគុណ គប្បីនាំគ្នាចងសាមគ្គី រក្សាឯករាជ្យ ជួតដៃគ្នាកសាងប្រទេសជាតិ ដើរតាមគម្រោងដែលព្រះអង្គទ្រង់គ្រោងទុកមកហើយ ទុកព្រះអង្គជានាយកនាវិកដ៏ឆ្នើម ទឹងជានាយបញ្ជាការដ៏វិសេស សម្រាប់ប្រទេសអស់កល្បាវសានតទៅកុំបីឃ្លាតឆ្ងាយទៅជាប្រការដទៃឡើយ ។

សមណនិស្សិតខ្មែរ នៅធម្មទូតមហាវិទ្យាល័យក្រុងរង្គូន សហភាពភូមា ។

ភិក្ខុ សីលគុត្តោ (ថោង-ទិត



សាសនាជៃន និងពុទ្ធសាសនា

បណ្តាសាសនាធំៗ ដែលកើតមាននៅក្នុងប្រទេសឥណ្ឌា សាសនាជៃន ក៏ជាសាសនា មួយមានអាយុវែង ហើយមានជនកាន់ច្រើន ដ៏ពេញនិយមសព្វថ្ងៃនេះ ។ ប៉ុន្តែសាសនានេះ ពុំអាចផ្សាយតទៅតាមប្រទេសនានា ក្រៅពីប្រទេសឥណ្ឌាបានទេ ព្រោះប្រទេសស៊ីវិលាយ៉ាងខ្លាំងផ្សាយក្នុងលោក ពុំអាចប្រតិបត្តិតាមសាសនានេះបាន ដោយសាសនានេះ ប្រកាន់ធម៌អត្តកិលមថានុយោគខ្លាំងពេក ។ អ្នកបួសប្រព្រឹត្តអាក្រាត, ប្រព្រឹត្តដកសក់ដោយសណ្ឋាស ឬដោយវ៉ត្តផ្សេងៗ មានគ្រាប់ត្នោតជាដើមដែលអាចដកបាន, បរិភោគអាហារក្នុងដៃ ពុំមានចានត្រ ឬភាជន៍អ្វីឡើយ, រដូវរងាប្រព្រឹត្តធ្វើតប:ក្នុងទីម្ចាស់ត្រជាក់, លុះរដូវក្តៅប្រព្រឹត្តធ្វើតប: ឥណ្ឌាលវ៉ាលហាល

ដ៏ថ្ម, ប្រពឹត្តមិនធ្លុតទ៉ឹកប៉ុណ្ណោះជាដើមជាហេតុធ្វើឲ្យមានកម្លាំងខ្សោយក្នុងការផ្សាយផ្ទៃ-ពលទៅកាន់ការប្រទេសនានាក្នុងលោក ។

អ្នកប្រាជ្ញខាងសាសនាជាតិអាល្លឺម៉ង់ដ៏ម្នាក់ឈ្មោះម៉ូរីសវ៉ីន្ទ្រីនីត្ស (Maurice vinter-nitz) ជាអ្នកសរសេរសៀវភៅឈ្មោះ ប្រវត្តិវណ្ណគតិផ្លូវ History of Indian Literoture) បានបញ្ជាក់ថា សាសនាជៃនជាសាសនាចំណាស់ គឺផ្សាយបានតែក្នុងប្រទេសតូចមួយ, ឯពុទ្ធសាសនាជាសាសនាសកល អាចផ្សាយទៅកាន់ទីណាក៏បាន ។

ប៉ុន្តែប្រជាជនប្រមាណ ១០ ភាគរយក្នុងប្រទេសតូចមួយ នៅប្រកាន់ជ្រឹះជ្រៅអានសាសនានេះយ៉ាងជិតស្និទ្ធ ដោយយល់ថាសាសនានេះប្រកាន់ធម្មសាស្ត្រ និងខ្ពស់ យ៉ាងខ្ពង់ខ្ពស់ ហើយមានប្រជាជាតិទស្សនវិស្វ៊ីជ្រាលជ្រៅផង ។

តាមដំណឹងសាសនា ថាសាសនាជៃនបានកើតឡើងមុនព្រះពុទ្ធសាសនាបន្តិចដោយសារស្តេចឈ្មោះមហាវ៉ីរៈ ឬ និគណ្ឋនាដបុត្ត (តាមដែលមានមកក្នុងគម្ពីរពុទ្ធ ១៨ សាសនា) ។ អ្នកប្រាជ្ញខាងសាសនាជៃនបានកត់ប្រវត្តិទុកថា មហាវ៉ីរៈ បានប្រសូតចេញពីផ្ទៃមាតា មុនគ្រិស្តសករាជ ៥៩៩ ឆ្នាំ, ចេញបួសអាយុ ៣០ ឆ្នាំ, ផ្ទៃក្តីកំរិយាអស់ ១២ ឆ្នាំ បានសម្រេចកេវលកញ្ញាណ (គឺញាណដែលខ្ពស់ បំផុតរបស់មហាវ៉ីរៈ) ក្នុងអាយុ ៤២ ឆ្នាំ, និញ្ជានក្នុងអាយុកាល ៧២ ឆ្នាំ គឺក្នុងឆ្នាំ ៥២៧ មុនគ្រិស្តសករាជ ។ (ពួកជៃនិកសារ៉ែកជ្រឿជាក់ថា មហាវ៉ីរៈបានសម្រេចនិញ្ជានដូចជាព្រះពុទ្ធដែរ) ។

មហាវ៉ីរៈកើតមុនព្រះពុទ្ធជាម្ចាស់ឬ?

អំពីការកើតមុនក្រោយនៃពុទ្ធសាសនានឹងសាសនាជៃន និងសូមពណ្ណនាជាខាង

ក្រោយ ។ ទីនេះសូមពណ៌នាអំពីមហាវីរៈ នឹងព្រះពុទ្ធ, ណាកើតមុន ណាកើតក្រោយ, ដែលតែងមានការកាន់ប្រទ្សាន់ធ្ងន់ធ្ងរមត់គ្នាជាប្រចាំ ។

ពុទ្ធសាសនាចាប់ពីត្រឹមព្រះពុទ្ធបរិនិព្វានថយក្រោយបាន ៥៤៣ ឆ្នាំ ៥៤៤ ឆ្នាំមុនគ្រិស្តសកពជ, បើចាប់តាំងពីព្រះអង្គប្រសូត្រ ៨០ ឆ្នាំបញ្ចូលផង បាន ៦២៣ ឆ្នាំ ៦២៤ ឆ្នាំមុន គ. ស. ។ ដូច្នេះបើធៀបនឹងឆ្នាំកំណើតរបស់មហាវីរៈ ដូចពណ៌នាខាងដើម (៥៩៩ ឆ្នាំមុន គ.ស.) យើញថាព្រះពុទ្ធជាម្ចាស់កើតមុនមហាវីរៈ (និគណ្ឋនាដបុត្ត) ។ ប៉ុន្តែ គម្ពីរពុទ្ធសាសនាយើង ដូចក្នុងសាមញ្ញផលសូត្រ (ទីឃនិកាយ) ជាដើម ប្រើនពណ៌នាដែលអាចនាំយកសេចក្តីបានថា មហាវីរៈ មានអាយុប្រើនជាងព្រះពុទ្ធជាម្ចាស់ ។ ទោះបីយ៉ាងនោះក៏មិនខ្វល់គ្នាច្រើនណាស់ណាទេ ព្រោះអាចនាំសន្ទូតបានជាព្រះពុទ្ធជាម្ចាស់ នឹង មហាវីរៈ បានត្រាស់នឹងផ្សព្វផ្សាយសាសនាក្នុងជម្ពូទ្វីប ក្នុងយុគសម័យជាមួយគ្នា ដោយមានអាតត្តជ្ញានជាប្រើនក្នុងសុត្តន្តបិដក ។

ប៉ុន្តែ មានអ្នកនិពន្ធខ្លះ ដោយការភ្លាត់គំនិតម្តងដោយពុំបានពិចារណាឲ្យសមហេតុសមផល ចូលចិត្តសរសេរថា «មហាវីរៈ ជាសាស្តាបស់ពួកនិគ្រន្ថតិ្ថ៍យ៍ កើតមុនព្រះពុទ្ធជាម្ចាស់យើងជាប្រើនរយឆ្នាំ» ។ ពាក្យថា «ប្រើនរយឆ្នាំ» ក្នុងទីនេះ បើយ៉ាងតិចក៏ពីរ ឬ បីរយឆ្នាំ ។ ក្នុងរឿងនេះសូមត្រិះរិតាមវិចារណានិយដូចតទៅ ៖ មនុស្សសម័យនោះមានអាយុកម្សាន់ប៉ុន្មានឆ្នាំ? , បើមហាវីរៈ កើតមុនព្រះពុទ្ធជាប្រើនរយឆ្នាំ តើអាចមានអាយុវែងដល់ពុទ្ធកាលឬ?, ឬក៏អស់អាយុមុនពុទ្ធកាល? ក្នុងសុត្តន្តបិដក មានអាតត្តជ្ញានជាប្រើនកន្លែងដែលពណ៌នា អំពីការសួរនាំទស្សនៈគ្នាទៅវិញទៅមករវាងនិគណ្ឋនាដបុត្ត គឺមហាវីរៈ នឹងព្រះពុទ្ធជាម្ចាស់ ដូចក្នុងទុតិយសូត្រ,

អកយសូត្រ (មជ្ឈិមនិកាយ) ជាដើម ពុំមែនឬ? បើដូច្នេះតើនឹងរិនប្ដូយបែបណា ឲ្យសមហេតុសមផល? ។

សាសនាជៃន ត្រូវកដជាកើតមុនពុទ្ធសាសនាប្រាំនរយ ឬ ប្រាំនពាន់ឆ្នាំមែន?

ជៃនិកបណ្ឌិតឈ្មោះអមរចន្ទ (Amar chand) បានសរសេរថា មហាវីរ: ពុំមែនជាសាស្ដាដើមនៃប្រជុំផ្ដុតរបស់សាសនាជៃនទេ គឺជាសាស្ដាទី ២៤ ក្រោយគេបំផុត, គេហៅថា តីត្ថ្ងៃ (អ្នកស្ថាបនាទ្រូលិទ្ធ ឬ ទីពឹ) ទី ២៤ ។ ឯតីត្ថ្ងៃ ២២ រូបខាងដើម អ្នកនិពន្ធនោះពុំបានពោលដល់, គេនិយាយតែអំពីតីត្ថ្ងៃទី ២៣ ឈ្មោះបាស្វ៊ីនាថ ។ សាស្ដាបាស្វ៊ីនាថ បានប្រកាសប្រាំងយ៉ាងខ្លាំង បំពេះការប្រព្ឤត្តលាមកជាគម្រប់ក្នុងសង្ឆ ព្យាយាមលើកសង្ឆមធ្វើសង្ឆមឲ្យបរិសុទ្ធ ប្រមាណ ២៥០ ឆ្នាំមុនមហាវីរ: ។ ប៉ុន្ដែកាលសាស្ដា បាស្វ៊ីនាថអស់អាយុទៅ សង្ឆមក៏បានធ្លាក់ចុះក្នុងគម្រប់លាមកវិញដូចដើម, តែនៅមានអ្នកបួសតាមសាស្ដានោះខ្លះ ។ ដរាបដល់មហាវីរ:កើតទៀង ។ ប្រវត្ដិបានពណ៌នាថា សូម្បីវង្សត្រកូលរបស់ មហាវីរ: ក៏ធ្លាប់ជាសាវ័ក ឬ ជាបរិស័ទនៃ សាស្ដា បាស្វ៊ីនាថ ។ គ្នាតាំងពីដើមរៀង ។ មក ។

តទៅសូមអានដីវប្រវត្ដិសង្ខេបរបស់មហាវីរ: ដែលបានដកស្រង់ពីអាគតស្ថានផ្សេង ។ ដែលអ្នកត្រូវជូនាងសាសនាជៃន បានសរសេរទុកមក ៖

ជាតិភូមិ និងវង្សត្រកូលរបស់មហាវីរ:

មហាវីរ:កើតក្នុងកុណ្ឌ្ឌ្ឌ្ឌ ដ៏តក្រុងវ៉ៃសាលី, ប្រមាណ ២៨ មៃល៍ (ប្រហែល ៤០ គ.ម.) ខាងជើងក្រុងបត្ន:, ឥណ្ឌៀសម័យបច្ចុប្ប្ន, ក្នុង ញាតិកខត្ដ្ដិយត្រកូល, ដ្ឋលកាលហៅថានាយត្រកូល (ចានជាពេលក្រោយមកគេហៅមហាវីរ: ថា នាថបុត្ដ)

ក្នុងកសត្រៀបគ្រាត្រ ។ បិតាឈ្មោះសុទ្ធោទ (ពុំមែនសុទ្ធោទ គឺព្រះពុទ្ធទេ) ជនជាតិ គេហៅថា ស្រីយ៉ាំ:ម្ហ យ៉ាំ ។ មាតាឈ្មោះព្រះនាងត្រីសាលាជនជាតិគេ ហៅថា រ៉ៃទេហទត្តា ឬ ប្រ៉ៃយ៉ាកានី, កើតក្នុងវិស័យគ្រាត្រ ។ ព្រះនាងជាព្រះពាជកគិនី នៃព្រះចាទ្ទេបេជក ។ សោយពាជ្ជនៅនគ:រ៉ៃទេហ: ។

ក្នុងឆ្នាំ ៥៩៩ មុនគ.ស. ថ្ងៃ ១៣ កើតខែចៃត្រ មហាវីរ: បានប្រសូត្រចេញពីផ្ទៃ មាតា គឺនាងត្រីសាលា, ប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ទាំងមាតា ទាំងបុត្រ ។ គម្ពីរជនឈ្មោះកល្ជសូត្រ បានពណ៌នាយ៉ាងវែងអំពីការសម្រាយរីកពាយសុខក្សេមក្នុងវង្សត្រកូល, ពន្ធ:ស្ម:ព្រាងព្រាតក្នុងទ:ទ:ស:ដ្ឋានទ:ងតាមវ:ថី, ការដោះលែងអ្នកទោស ទ:ងការបរិច្ចាគទានយ៉ាងអធិកអធម ក្នុងថ្ងៃកំណើត នៃទារកមហាវីរ: ។

នាមទ:ងនាមបញ្ញត្តិ:ជ:ស់មហាវ:

ព្រះសម្ម:ាសម្ពុទ្ធ ជាម្ចាស់យើង មាននាមទ:ងនាមបញ្ញត្តិ:ច្រើន ជ:ចកាលពីតូចមាន គេហៅថា សិទ្ធត្ថ គ្រាតមជាដើម, លុះបានសម្រេចសម្ម:ាសម្ពោធិញ្ញាណហើយ បាននាមបញ្ញត្តិ:ថា អ:រហ: សម្ម:ាសម្ពុទ្ធជាដើម យ៉ាងណា, មហាវីរ: ក៏យ៉ាងនោះដែ:ល ។ ជ:ណាមានកាលនៅជាកុមារគេហៅថា វ:ឌ្ឍមាន: (ជាជាតិ:ឌ្ឍ:ណ) , រ៉ៃទេហ: (ជាបុត្ត:ស់នាងរ៉ៃទេហទត្តា) , ។ ជ:ណាមានសម្រេចញ្ញាណ ៥ ប្រការ:ហើយ គេហៅថា អ:រហ:ត្ត (អ្នកគ:ួ:ដ:ល់ការគោ:ព) , អ:ហ:ន្ត: (អ្នកកំចាត់ សត្រូ:) , អ:ហ:ន្ត: (អ្នក:ំលើងនូ:ប:ូ:ណ:ល់នៃកម្ម) , សាសន នាយក: (ជានាយក ឬ ប្រធាននៃសាសនា) ពុ:ទ្ធ: (អ្នកភ្ញាក់:ល:ឹ ឬអ្នកសម្រេចនូ:ញ្ញាណជ:ន់ខ្ព:ស់) ។ (ញ្ញាណ ៥ ប្រការ:ទ:ងមានពណ៌ាងាងក្រោយ) ។

(នៅមានត)

ពិធីបុណ្យឆ្លងផ្ដួលសង្គាយនា (ត)

មុនពេលបើកសម័យប្រជុំបន្ទិច លោកនាយកពិបុលសង្គ្រាមព្រមទាំងលោកស្រី នឹងក្រុមបេសកជនសុសពោត្តនារបស់ថៃ បាននលើកជូននូវព្រះពុទ្ធបដិមាករជាវិការនៃទង់ដែងមួយព្រះអង្គទៅលោកនាយករដ្ឋមន្ត្រីប្រទេសភូមា ដើម្បីជាទីរឭកនៃសង្រាមសន្និបាតនឹងទុកជាទីគោរពនមស្ការនៃពុទ្ធមាមកជនជាតិភូមាផង ។

សម័យប្រជុំលើកនោះបានបើកឡើងដោយលោកនាយករដ្ឋមន្ត្រីប្រទេសថៃ ហើយបានសម្ដេចព្រះវនរ័តន៍កិត្តិសោភ័ណ សង្ឃនាយកប្រទេសថៃជាប្រធាននៃព្រះសង្ឃជាសង្គីតិការកៈ ។

ស្រីលង្កាសន្និបាត

៥– បញ្ចមសន្និបាតឈ្មោះថាស្រីលង្កាសន្និបាត គឺសន្និបាតរបស់ប្រទេសស្រីលង្កា ឬ លង្កាទ្វីប, បានផ្ដើមពីថ្ងៃ១៣កើតខែចេត្រព.ស.២៤៩៩ (២៣មេសាគ.ស. ១៩៥៦) រហូតដល់ថ្ងៃ១៥កើតខែពិសាខ ព.ស.២៥០០ (១) (២៤ឧសភាគ.ស. ១៩៥៦) ទើបបប់ អស់រយៈកាល៣១ថ្ងៃគត់ ។

សម័យប្រជុំបានបើកឡើងដោយលោកជយវីរកុរុញ្ញ រដ្ឋមន្ត្រីក្រសួងធម្មការនឹងសិល្បករប្រទេសស្រីលង្កា, ក្នុងពេលនោះ សម្ដេចព្រះមហានាយក វេលិ-វិត ធម្មិកតិ អសរណសរណស្រីសរណង្ករគណៈសង្រាមនិកាយនៃប្រទេសស្រីលង្កាជាប្រធានសង្ឃ ។

ឯការបំណាយទៅលើសន្និបាតទាំង៥លើកនោះអស់បរិការជាតិយ៉ាងច្រើន ដែលប្រទេសពុទ្ធសាសនិកដូចគ្នាពីបាកនឹងធ្វើតាមបាន ដោយហោចសូម្បីតែការបំណាយ

---

(១) គ.ស. នៅប្រទេសភូមា២៥០០ក្នុងឆ្នាំនេះ តាមសេចក្ដីយល់ផ្សេងពីយើង

ទៅលើចង្ហាន់ព្រះសង្ឆ ជាសង្ខ្ចិតការកៈ ក្នុងមួយថ្ងៃកេងកត្ត្រូវចាយ ៣.០០០ក្បាត់ចាត់ ចែងចង្ហាន់ព្រះសង្ឆ សង្ខ្ចិតការកៈ ៩០០អង្គ ចុះបើកាប់តាំងពីថ្ងៃទី ១ នៃបឋមសន្ទិ្ធតរហូតដល់ថ្ងៃទីបំផុតនៃបញ្ចមសន្ទិ្ធតតើអស់ប៉ុន្មានទៅ ? បើសន្ទិ្ធតទាំង ៩ លើកមានចំនួន ២៤៨ ថ្ងៃ ។ យើញថាមុខចំណាយទៅចង្ហាន់អស់ ៧៤.០០០ក្បាត់ ។

ម្យ៉ាងទៀត នៅពេលបញ្ចប់ធម្មសង្ឆាយនាជាពេលពាក់កណ្តាលនៃព្រះពុទ្ធសាសនា រដ្ឋាភិបាលទឹកប្រជាជនជាតិកូមាបានប្រើងចាត់ចែងពីធីបុណ្យមួយយ៉ាងធំឈ្មោះថាបុណ្យពុទ្ធជយន្ទី ឬ បុណ្យ ២៥០០ ព្រះវស្សានៃព្រះពុទ្ធសាសនារួមជាមួយនឹងបុណ្យធ្វើធម្មសង្ឆាយនានោះឯង ។

ពិធីបុណ្យកំណត់ចូលពីថ្ងៃ ១៣ កើតខែពិសាខ ព.ស. ២៤៩៩ (២២ ឧសភា ១៩៥៦) ដល់ថ្ងៃ ៣ រោចខែពិសាខ ព.ស. ២៥០០ (២៧ ឧសភា ១៩៥៦) ។

មុនពេលចូលបុណ្យ គណកម្មការចាត់ចែងបុណ្យបានអំពាវនាវសុំឲ្យរដ្ឋាភិបាលដោះបន្ធយទោសពីអ្នកជាប់ទោសក្នុងអាណាចក្រឲ្យបានថយចុះគ្រប់ថ្នាក់នៃទោស ។ រដ្ឋាភិបាលក៏បានអនុម័តយល់ស្រមបតាមនោះ ហើយដោះបន្ធយទោសនៃអ្នកទោសគ្រប់ពន្ធនាគារដែលជាប់ទោសក្នុងពេលមុនថ្ងៃ ១២ ឧសភាគ.ស. ១៩៥៦ ទៅតាមលំដាប់ថ្នាក់នៃទោសធ្ងន់ស្រាល ។

ការបន្ធយទោសនោះគឺ ៖

១ – អ្នកមានទោសមួយជីវិតត្រូវបន្ធយមកត្រឹម ១០ ឆ្នាំ ។

២ – អ្នកមានទោសលើសពី ១០ ឆ្នាំទៅដល់ ២៥ ត្រូវបានថយមកនៅត្រឹម ៣ ឆ្នាំ ។

៣ – អ្នកមានទោសពី ២ ឆ្នាំទៅដប់ឆ្នាំត្រូវបន្ធយ ៣-៤ (ភាគក្នុង ៤) គឺបើជាប់

១០ ឆ្នាំត្រូវថយមក២ឆ្នាំកន្លះ, ៤ឆ្នាំត្រូវថយមក៦ខែ ។

៤– អ្នកមានទោសពីត្រឹម៦ខែចុះមកត្រូវបានរួចខ្លួន ។

រដ្ឋាភិបាលបានប្រកាសឲ្យដោះលែងអ្នកទោសស្រាលៗ ទាំងនោះក្នុងពេលមុនបុណ្យ៤ថ្ងៃ ដើម្បីឲ្យអ្នកទាំងនោះមានពេលទៅជួបជុំគ្រួសាររបស់ខ្លួន ហើយនឹងបានរៀបចំដំណើរទៅធ្វើបុណ្យនោះនឹងគេ ។

ឯមុខការងាររដ្ឋាភិបាលបានឈប់ផ្អាកបីថ្ងៃ គឺពីថ្ងៃទី ២៣ ដល់ ២៥ ឧសភា គ.ស. ១៩៥៦ ។

ដទៃពីនោះ រដ្ឋាភិបាលបានហាមប្រាប់ប្រជាជនមិនឲ្យធ្វើអាឃាតសត្វគឺសុំឲ្យប្រជាជនឲ្យអភ័យដល់សត្វទៅក្នុងពេលបុណ្យ មិនតែប៉ុណ្ណោះអាឃាតនដ្ឋានទាំងអស់នៅទីក្រុងវង្គនឹងខែត្រក្រៅត្រូវបិទរវាំង៣ថ្ងៃ ។

នៅថ្ងៃ១៣កើតខែពិសាខ ព.ស.២៤៩៩ (២២ ឧសភា គ.ស.១៩៥៦)ពិធីបុណ្យបានបើកឡើង ។ ថ្ងៃនោះជាពេលមាននក្ខត្តឫក្សដ៏អស្ចារ្យដែលក្នុងប្រវត្តិសាស្ត្រភូមាពុំដែលមាន គ្រប់គេស្ថាននៅក្នុងទីក្រុងនឹងខែត្រក្រៅមានដោតទង់ជាតិនឹងទង់ឆព្វណ្ណរង្សីដែលជាសញ្ញានៃទង់សាសនាពីមុខ ហើយនៅពេលយប់មានប្រទីបផ្កាលាក្លូព្រោងព្រាតវិចិត្រជាក្បាច់ក្បូរផ្សេងៗ ។

នៅលើទួលសិរីមង្គលា បរិយាកាសយ៉ាងត្រជាក់ស្រទន់បានគ្រប់ដណ្តប់ពីលើសន្សើមៗ បន្តិចម្តងៗ ឯផ្នែកការិយាល័យមហាមេឃក៏បានបញ្ចេញពណ៌ស្អាតខៀវស្រងាត់គួរជាទីត្រជាក់ចិត្តនៃសព្វសត្វ ទាំងពុទ្ធមាមកជនក៏ក្លកក្លឹកទាំងនាម៉ឺនទាំងរាស្ត្រ, ចាស់ក្មេង, ក្រមុំ-កំឡោះ, ប្រុស-ស្រីដែលមកពីទិសតធ្ងាយនៃរដ្ឋទាំងអស់ក្នុងសហភាពភូមាៗ

តាមដំណឹងនៃសាពតិមានឈ្មោះ (Burma Star) ផ្ទាយកូមាថាមានប្រមាណជាង ១០០០.០០០ (១០ម៉ឺន) នាក់ ។ ប្រជាជនទាំងនោះ ខ្លះក៏ជៅដោយរថយន្ត ខ្លះក៏ជៅដោយគោចក្រយាន អ្នកខ្លះក៏ដើរ ពាក់ពពួនគ្នា ពួកខ្លះមានមុខាញ្ចុះជៅ មហាចាសាណេគុហាខ្លះសំដៅជៅខាងក្រុមរោងតាំងវត្ថុផ្សេង ។ ក្រុមខ្លះទៀតក៏សំដៅជៅកកន្ទ្រងជប់លៀងដែលសមាគមធំ ។ នៅកន្លែងក្រុងរ៉ង្គូនបានរៀបរោង ៤ កន្ទ្រងយ៉ាងធំ ។ សម្រាប់ទទួលជប់លៀងភ្ញៀវជនាហារពួកមកជនទាំងឡាយដែលមកពីទីដ៏ឆ្ងាយ ដោយឥតយកថ្លៃ ដើម្បីជាកិត្តិយសដ៏ខ្ពស់ក្នុងនៃបុណ្យបញ្ចប់ធម្មសង្ហាយនានឹងបុណ្យពុទ្ធជយន្តីនោះឯង ។

បំណែកព្រះសង្ឆក៏ចេះតែនិមន្តមកគ្រឹក ទាំងព្រះសង្ឆដែលគណកម្មការបុណ្យនិមន្តមកនឹងព្រះសង្ឆក្រៅពីការនិមន្ត ។ ព្រះសង្ឆដែលគណ:កម្មការនិមន្តមកទទួលទេយ្យវត្ថុបំនួន ២.៥០០ អង្គ ដោយទីមហាកុដិទាំង ៤ ដាក់ចូលតែ ១.៥០០ អង្គ ទើបគណ:កម្មការរៀបមហាវិទ្យាល័យក្នុងក្រុងរ៉ង្គូន ដើម្បីព្រះសង្ឆ ១.០០០ អង្គទៀត ។ ប៉ុន្តែនៅតែខ្វះទីកន្ទ្រងព្រះសង្ឆសឹងទៀត គណ:កម្មការក៏ចាត់ចែងរៀបមហាកុដិទាំងបួននោះឲ្យសឹងក្នុងមួយបន្ទប់ ៤ អង្គ លើកតែមហាថេរដែលមានវស្សា ៤០ឡើងជៅគេរៀបប្រគេនមួយបន្ទប់ ២ អង្គ ។

ក្នុងពេល អង្គាសចង្ហាន់ក៏រៀបអង្គាសជាពីរផ្នែកមួយផ្នែកនៅខាងធម្មសង្ហាយនដ្ឋានមួយផ្នែកទៀតនៅនឹងមហាវិទ្យាល័យនោះឯង ។ នៅពេលបុណ្យនោះពលការចូលបរេញ្ញកឆ័ទតាដើងទឹកប្រមាណ ១.០០០ នាក់មកបំរើព្រះសង្ឆរាល់ពេលឆាន់ទឹកនៅពេលរាសៀលជួយសែងទេយ្យវត្ថុដែលពួក ១ចាសក - ១ចាស៊ីកា អ្នកមានសទ្ធាជ្រះថ្លាប្រគេនលាកនៅក្នុងចាសាណគុហា ។

(នៅមាន ត)

តែឯព្រាយនៅប្រាង្គចេតិយធំទិសអគ្នេយ៍នោះ មានពណ៌សម្បុរខ្មៅបានហោះមក ផ្ទួលៗ តែមិនបានចូលមកក្នុងដែនសីមា ហើយក៏ហោះត្រឡប់វិលទៅប្រាង្គនោះវិញ ទាក់យកមិនបានសោះធ្វើតែយ៉ាងនេះពីរបីដង ព្រាយនេះរបីងរើផងព្រាយឯទៀត បានជាគាត់ប្រាប់ថាពូកែណាស់ប្រាង្គចេតិយធំនៅទិសអគ្នេយ៍នោះ ។

នៅទិសខាងត្បូងចម្ងាយ ១០ ម៉ែត្រពីហៀនវិហារធំនេះមានអាស្រមមួយ ១ខ្នង ដែលគេកសាងលើដីលើកខ្ពស់ប្រហែលជាកំពស់ ២ ម៉ែត្រគន្ធទូសម្រាប់ដំកល់ព្រះបាទនៃព្រះសម្មាសម្ពុទ្ធ ដែលគេបានកសាងអំពីសិលាជាតិ ជាបាទលញ្ឆនៈស្នាមគំនូសចម្លាក់ប្រទាក់ដោយលក្ខណៈរូបផ្សេងៗ មានបណ្តោយជាង ១ ម៉ែត្រ ទទឹង ១ ម៉ែត្រ បទមាសលាបជាតិជ័រហ៊ុំលគេលើកដំកល់រានតាំង ១ ធំ ដែលគេធ្វើអំពីក្រាក់ខ្លឹមឈើទុកជាអនុស្សាវរីយ៍ជាទីធ្វើនមស្សការរបស់ពុទ្ធបរិស័ទ, នៅខាងក្រោយព្រះបាទនេះមានផែនថ្ម ២ ផ្ទាំង មួយផ្ទាំងបន្ទារសំប៉ែតធំពងជាសីមា មួយផ្ទាំងទៀតជាផែន ៤ ជ្រុងស្មើកំពស់ប្រហែល ១ ម៉ែត្រ មានពណ៌សម្បុរខ្មៅដូចថ្មអណ្តើក(១)ហើយចារិកសរសេរអក្សរខ្មែរទាំង ៤ ជ្រុងយ៉ាងស្អាតក្រៃលែង ជាគាថាភាសាបាលីសំស្ក្រិតជាង ១០០ គាថា ដំណាលពីព្រះបាទជ័យវរ្ម័នទី ៥ ដែលទ្រង់បានរៀបចំកសាងដួសដុលព្រះពុទ្ធរូប និងទេវរូប ហើយបានដំកល់ទុកឲ្យមានរបៀបរៀបរយល្អតរៀងមកដល់សព្វថ្ងៃនេះ ។

តាមដំណើរនិយាយតៗគ្នាមកថា: ព្រះបាទព្រះដែលគេបានដំកល់ទុកនូវទីចារិកនោះ គឺព្រះបាទព្រះរបស់ព្រះចៅស្តេចលាវសម័យដើម ដែលទ្រង់បានចាត់ព្រះរាជបំរើឲ្យហែនាំយកព្រះបាទព្រះនេះ ១ ដើមជ្រៃលាប ដែលរលំស្លាប់ទៅដោយជរាឆ្នាំហើយ ១

(១) ប្រហែលទៅឆ្នាំ ១៩៥២ មានចោរហ៊ានលបលួចទីនោះបាត់ទៅហើយ

មកថ្វាយជាធម្មបណ្ណាការ ទុកជាសក្ការៈគោរពបូជាចំពោះធម្មទេសនារបស់ព្រះមហា-ថេរ ១ អង្គជាជាតិក្សត្រិយ៍ទ្រង់ព្រះនាម អេង្គ កេម, ដែលទ្រង់លះរាជសម្បត្តិចេញសាងផ្នួសជាបព្វជិតខំប្រព្រឹត្តរៀនធម៌ព្រះអភិធម្មទាល់តែចេះចាំស្ទាត់រត់មាត់ ហើយទ្រង់គង់ទេសនានៅវត្តឯកទេសដែលក្លាយយារមកហៅថា វត្តផ្នែកទេសន៍ ថ្វាយទៅព្រះចៅស្តេចស្រុកលាវ ព្រះចៅទ្រង់ជ្រះថ្លាដោយព្រះរាជសទ្ធាយ៉ាងខ្លាំង ទើបថ្វាយព្រះបាទព្រះនឹងដើមជ្រៃណាបនោះមកទុកជាអនុស្សរណីយវត្ថុរបស់ទ្រង់ ។

លុះកាលកន្លងទៅដាច់ស្រយាល នឹងរកមនុស្សណាម្នាក់សួរការណ៍ឲ្យអំពីលំដាប់ចៅអធិការវត្តព្រះរាជនិវេសនដ្ឋាននេះឲ្យពិតប្រាកដពុំបាន ទើបលោកព្រះគ្រូវិរិយមុនីសៅ-មៀច ដែលកើតនៅស្រុកនោះ បានដំណឹងថាក្នុងរវាងជាង ១០០ ឆ្នាំកន្លងទៅហើយ ពួកយាយ-តា ដំណាលប្រាប់លោកថា: មានលោក ១ អង្គព្រះនាម ទេព ធ្វើជាចៅអធិការវត្តនេះ តពីសង្ឃរាជទេពនោះមក, លោកគ្រូព្រះនាម ស្រី ធ្វើជាចៅអធិការតពីលោកគ្រូព្រះនាមស្រីនោះមក លោកគ្រូព្រះហ៊ីង ធ្វើជាចៅអធិការ មានឋានាថាព្រះបាឡាត់គណដែលព្រះករុណាព្រះសុវណ្ណកោដ្ឋទ្រង់តាំងឲ្យ តពីលោកគ្រូ-ហ៊ីងនោះមក លោកគ្រូព្រះនាម ខៀវ ធ្វើជាចៅអធិការ ។

វត្តនេះក៏ដល់នូវភាពធ្លាក់ចុះកិត្តិយសទន់ខ្សោយ ដោយមានបព្វជិតត្រឹមតែ ២-៣ ៤ អង្គប៉ុណ្ណោះ ព្រោះពុំមានការសិក្សាធម៌វិន័យដែលជាផ្លូវបំភ្លឺពន្យល់ដល់បព្វជិតទាំងនោះ ឲ្យបានចេះដឹងស្គាល់ផ្លូវប្រតិបត្តិជាដំណើរទៅកាន់សេចក្ដីសុខ-ចំរើន ម្ល៉ោះហើយបព្វជិតទាំងនោះ វៀតបិត្តឃ្លាតចាកសេចក្ដីប្រតិបត្តិធម៌វិន័យ និងការចេះដឹង គេឃើញមានទីកន្លែងអយករណីកិច្ច និងកុក្កុករណីយកិច្ចក្នុងទីវត្តជាច្រើន ឯពួកកុមារកូន

ចៅអ្នកស្រុកដែលគេយកមកទុកដាក់ធ្វើឲ្យរៀនសូត្រអក្សរសាស្ត្រនៅវត្ត មិនងាយនឹងរៀនឲ្យបានចេះដឹងច្បាស់លាស់ កំណត់កាលនៅត្រឹម៣-៤ឆ្នាំ ទើបចេះមើលសាស្ត្រាយល់សេចក្តីកន្លះរៀងទីមួយ ៗ តែបន្តិច នៅមិនទាន់ចេះសរសេរអក្សរក្រៀងរៀងសេចក្តីណាមួយឲ្យបានមធ្យមពុំទាន់កើត ហើយច្រើនតែមានអាយុ ១៦-១៧-១៨-១៩-២០ឆ្នាំទើបទៅនៅវត្តសិក្សារៀនអក្សរសាស្ត្រ ទាំងជួយធុរៈប្រកបការហត្ថកម្មរបស់បព្វជិតទាំងនោះ, ចំណែកឯបព្វជិត រៀនបានតែធម៌មាតិកា ដែលពាក្យអ្នកស្រុកហៅថាធម៌ផាះបុស្សតួបរិត្តគឺធម៌សូត្រមន្ត បួសបានត្រឹម៣-៤ វស្សាប៉ុណ្ណោះក៏លាចាកសិក្ខាបទទៅជាគ្រហស្ថរកស៊ីធ្វើស្រែចំការ ពុំសូវមានអ្នកបួសនៅរក្សាវត្តនោះច្រើនអង្គទេ ជួនកាលមានត្រឹមតែ ១ អង្គ ជួនកាលក៏ដាច់សូន្យគ្មានភិក្ខុអ្នកនៅគ្រប់គ្រងវត្តនោះសោះម៉្លោះហើយសេចក្តីបរិវត្តកើតឡើងដល់ឧបាសក-ឧបាសិកា អ្នកកាន់ព្រះពុទ្ធសាសនារិះរកនិមន្តលោកធ្វើចៅអធិការដើម្បីរក្សាវត្តព្រះរាជនិវេសន៍នដ្ឋាននេះតអំពីលោកគ្រូចៅអធិការព្រះនាម ខៀវ នោះមកទៀត ។

កាលពុទ្ធសករាជ ២៤២២ គ្រិស្តសករាជ ១៨៨០ ពួកក្រុមឧបាសក-សិកាវត្តស៊ីធរបានរួមគំនិតគ្នា ចាត់ឧបាសកម្នាក់ មានឋានៈក្នាក់ងារជាមេឃុំនៅឃុំស៊ីធរនេះឈ្មោះ (បញ្ញា-ចាប)ជាអ្នកមានសមត្ថភាពអង់អាច ហើយជាអ្នកធ្លៀវឈ្លាសក្នុងធម៌វិន័យជាងមនុស្សក្នុងស្រុកទាំងអស់ ឲ្យគាត់ចូលមកកាន់សំណាក់សម្តេចព្រះមហាសង្ឃរាជព្រះនាម (ទៀង) នឹងព្រះតេជព្រះគុណព្រះមហាវិមលធម្មព្រះនាម (ថោង) ជាចាងហ្វាងទី១ នៃសាលាបាលីជាន់ខ្ពស់ក្រុងភ្នំពេញ សុំនិមន្តភិក្ខុ១រូប ឲ្យស័ក្តិសមទៅលុមធ្វើជាចៅអធិការវត្តស៊ីធរនោះបាន សម្តេចព្រះមហាសង្ឃរាជនឹងព្រះតេជព្រះគុណព្រះមហា

វិមលធម្ម ក៏បានចាត់ភិក្ខុ១រូបព្រះនាម (ល្វី-ឯម) ព្រះជន្មាយុ២១ឆ្នាំ ទើបនឹងបួសជាភិក្ខុ កម្លោះថ្មី មានសរីរកាយស្អាតសមសួនទាំងដងខ្លួនក៏ពស់ក៏ពារមើលទៅមិនចាស់ក្មេក, លោកតា (បញ្ញា-ចាប) គ្រាន់តែក្រឡេកឃើញភិក្ខុ (ល្វី-ឯម) និមន្តមកថ្វាយបង្គំព្រះមហាវិមលធម្ម (ថោង) គាត់ក៏ត្រេកអរអស្ចារ្យក្នុងចិត្តគិតថា: អើះ! លោកនេះជាអ្នកប្រាជ្ញមុខជានឹងចេះដឹងធម៌វិន័យពិតប្រាកដឥតសង្ស័យ ព្រោះគាត់ជាអ្នកប៉ុនទាន់ស្គាល់លក្ខណៈសម្បត្តិ គិតថា: គេងក៏គេងប៉ុះ! ព្រោះមិនខុសពីចិត្តរបស់អញ គាត់មានសេចក្តីសោមនស្សរីករាយ បានទទួលនិមន្តភិក្ខុ (ល្វី-ឯម) អំពីសំណាក់សម្តេចព្រះមហាសង្ឃរាជនឹងព្រះតេជព្រះគុណព្រះមហាវិមលធម្ម ឲ្យទៅធ្វើជាចៅអធិការវត្តស៊ីធរ តពីលោកគ្រូចៅអធិការព្រះនាម ខៀវ នោះមក ។

ភិក្ខុ (ល្វី-ឯម) បានទទួលនាទីធ្វើជាចៅអធិការវត្តព្រះពុទ្ធនិវេសនដ្ឋានស្រីសឈរបំនួន១៣ឆ្នាំ បាននាមបញ្ញត្តិជាព្រះគ្រូវិមលបញ្ញា រឿនហ្វានក្រសួងសង្ឃ ដោយអំណាចសម្តេចព្រះមហាសង្ឃរាជព្រះនាម ទៀង ប្រទានថានៈជា ព្រះគ្រូវិមលបញ្ញា (ល្វី-ឯម) ចៅអធិការវត្តស៊ីធរ មានកិត្តិស័ព្ទល្បីល្បាញខាងការសំដែងធម៌ទេសនាជាវោហារគោសល្យផង ខាងការបង្ហាត់បង្រៀនព្រះបរិយត្តិធម៌ ពីត្រៃបិដកផង ខាងការបង្ហាត់ធម៌សូត្រឲ្យត្រឹមត្រូវតាមផ្លូវសំយោគគឺសង្កត់ឲ្យលំទប់បន្ដឹងបន្ទិចត្រង់អក្ខរៈណាដែលមានគួរព្យញ្ជនៈជម្រុតគ្នាឲ្យរត់មាត់ជាពួងមួយមិនឲ្យរអាក់រអួលផង ទាំងបង្រៀនអក្សរសាស្ត្រដល់ពួកកុមារដែលមកនៅសិក្សាផ្សាល់ នឹងចាត់ការរៀបចំវត្តអារាម ឲ្យបានរុងរឿងផង ដូចមានករណីយកិច្ចដែលយើងបានពោលរៀបរាប់តទៅនេះ

(នៅមានត)

ធនញ្ជយបណ្ឌិត (ត)

លុះព្រឹកឡើងព្រះរាជាឡើងគង់លើខ្នងហត្ថីបរចេញទៅតាមទ្វារកំពែងខាងកើត ។ ឯអស់ពួកមន្ត្រីតូចធំនឹងស្រីស្នំក្រមុំទាំងឡាយមាននាងអតុលាទេវីជាដើម ដែលជាចម្បងលើស្ត្រីមួយម៉ឺន៦ពាន់រូប មានសេចក្តីមេត្តាករុណាភិតភ័យអាឡោះអាល័យសោកស្តាយព្រះរាជា នាំគ្នាសំរក់ទឹកភ្នែកស្រែកទ្រហោទួញយំដំនុរ៉ា រំសាយសក់យំបំរះនរនៀលនឹងដីដើរតាមព្រះរាជាទៅ ៗ ឮស្ងូរតែសំឡេងយំទួយទ្រហឹងអឺងកង ដូចផ្គរលាន់ខែដើមឆ្នាំនោះឯង ។ តស្មិំ ខណេ ពោធិសត្តោ ធនញ្ជយកុមារោ ឯវំ សទ្ទំ សុត្វា ក្នុងគ្រានោះធនញ្ជយកុមារដែលជាអង្គពោធិសត្វឮស្ងូរសំឡេងយំយែកថ្ងូកអស្ចារ្យយ៉ាងនេះហើយ ក៏សួរធនញ្ជយសេដ្ឋីជាបិតាថា «ចុះឮសន្ធឹកអ៊ូអរទាំងម៉្លេះលោកឪពុក»? ឱ ! កូនប្រុសអើយមិនដឹងទេឬ? ព្រះករុណាជាម្ចាស់ជីវិតរបស់យើងព្រះអង្គមានទុក្ខធំណាស់កូន ! ជៀតដល់ថ្ងៃសន្មត ស្តេចយាងទៅឲ្យយក្សស៊ីថ្ងៃហ្នឹងហើយកូន ! បានជាមហាជនទាំងអស់យំស្តាយព្រះអង្គជាម្ចាស់ផែនដីដូច្នេះ ។

បើតបឹងខ្ញុំសូមទៅមើលគេបន្តិច ពោធិសត្វក៏ស្ទុះទៅ ៗ ឈរពាំងពីមុខហត្ថីព្រះទីនាំងហើយថ្វាយបង្គំប្រណម្យអញ្ជលី ក្រាបទូលសួរថា បពិត្រព្រះនរបតីស្រីសម្មតិទេពក្សត្រថ្ងៃប្រសើរជាអម្ចាស់ជីវិតលើត្បូង ព្រះអង្គមានហេតុទុក្ខភ័យដូចម្តេចព្រះអង្គ? ស្តេចក៏ទ្រង់ឆ្លើយតបទៅវិញថា: «អើ! ចៅអើយយើងមានទុក្ខធំណាស់យក្សវាចាប់យើងពី៧ថ្ងៃមុនវាប្រុងនឹងសម្លាប់បរិភោគជាអាហារទៅហើយ ៗ វាសួរមកយើងថា តើមានចេះមលតរធម៌ដែរឬទេ? បើពុំចេះទេវានឹងចាប់បរិភោគជាចំណីអាហារ ទើបយើងសូមអង្វរករយក្សមករកអ្នកប្រាជ្ញដែលចេះមលតរធម៌នោះឲ្យវាអស់ ៧ថ្ងៃ ឥឡូវនេះរកមិនបាន

សោះឡើយ បានជាយើងត្រូវទៅឲ្យយក្សបរិភោគខ្លួនឯង” ។ “បើដូច្នោះទូលព្រះបង្គំសូមទៅជំនួសព្រះអង្គ” ។ “ចៅឯងឈ្មោះអ្វី? នៅឯណា? ចេះមលតរធម៌ដែរ...?” “ក្រាបទូលឈ្មោះធនញ្ជយកុមារ បុត្រនាងសុខមាលីជាភរិយាធនញ្ជយ-សេដ្ឋី បុគ្គលក្នុងភពលោកក្រៅពីទូលបង្គំចេញ ឥតមាននរណាចេះទេ មានតែព្រះពុទ្ធទើបជ្រាបបាន ។ ដូច្នេះសូមសំលៀកបំពាក់សសុទ្ធប្រទានដល់ខ្ញុំព្រះអង្គ” ។ ស្តេចទ្រង់លើកព្រះពោធិសត្វដាក់លើទីនាំងហត្ថទន្ទឹមនឹងព្រះអង្គ ។ កាលណោះធនញ្ជយសេដ្ឋីនឹងនាងសុខមាលី ស្ទុះទៅឃាត់ព្រះពោធិសត្វថា កុំទៅអីកូនខ្លាចយក្សវាធំណាស់កូនឯងនៅតូចណាស់ វាស៊ីមិនស្កៀមជើងធ្មេញទេ ឱ! កូនកុំឲ្យទ្រូងម្ដាយផ្សាក្ដៅ លាព្រះអង្គចុះពីហត្ថីវិញមកកូន! ។ ទើបព្រះពោធិសត្វទ្រង់សំដែងធម៌ឲ្យមាតាបិតាជ្រះថ្លាពេញទៅដោយសោមនស្សរីករាយ ដោយសេចក្ដីឧបមាថា: ដូចជាសមុទ្រសាគរទុកណាជាមានខ្យល់ព្យុះបក់បោកយ៉ាងណា ក៏មិនអាចធ្វើទឹកសមុទ្ទសា-គរឲ្យរីងហួតបានឡើយ ខ្លួនខ្ញុំជាកូនតែងប្រកបដោយព្រហ្មវិហារផ្សាយទៅក៏យ៉ាងនោះដែរ ពុំនោះសោតដូចជាព្រះអាទិត្យ បើទុកជារាហ៊ូអាសូរិន្ទមកបៀតបៀនយ៉ាងណាក៏មិនបញ្ឈប់ដំណើរដើរក្រឡឹងព័ទ្ធពិភពលោកជាធម្មតា, ខ្លួនខ្ញុំឯងក៏យ៉ាងនោះដែរ ។ មាតាបិតាពោធិសត្វកាលបើឃាត់ពោធិសត្វជាបុត្រមិនបានដូច្នោះហើយ ក៏សូត្រមន្តឲ្យពរថា: “បិយ បុត្តក សព្វ សោត្ថិ សព្វ សុទ្ធិ សព្វ ជយោ ភវតុតេ ម្នាលកូនស្ងួនសំឡាញ់អើយ សេចក្ដីសួស្ដីទាំងពួងក្ដី សេចក្ដីសម្រេចសម្រិទ្ធិជោគសព្វយ៉ាងក្ដីជោគជ័យឈ្នះមារសត្រូវទាំងពួងក្ដីចូរឲ្យមានដល់កូនចុះ” ។ រួចក៏ត្រឡប់ទៅកាន់គេ-ហដ្ឋានវិញ ទាំងពីរនាក់ទៅហោង ។

គ្រានោះព្រះបាទកោរព្យរាជ កៀកធនញ្ជយកុមារឡើងគង់លើខ្នងហត្ថីទន្ទឹមគ្នា ហើយបរសំដៅទៅដើមជ្រៃនោះ លុះមើលឃើញដើមជ្រៃលិម ៗ ហើយស្តេចចង្អុលបង្ហាញពោធិសត្វថា នុ៎ះហ្ន៎! ចៅ! ជ្រៃហ្នឹងហើយ ចូរចៅទៅតែម្នាក់ឯងចុះ ។ ស្តេចព្រមទាំងបរិពារក៏ឈប់ពួននៅទីនេះទាំងអស់គ្នា ។ ពោធិសត្វជាកុមារតូចជិះលើហត្ថីស្ទើរតែមើលមិនឃើញ បរចូលទៅបានដល់ដើមជ្រៃនោះស្រែកហៅយក្សថា អីនទ្ទិយក្ស! យើងមកដល់ហើយ! ៗ ។ នទ្ទិយក្ស ជាអទិស្សមានកាយទេ លុះឮពាក្យសំដី ធនញ្ជយកុមារហៅខ្លួនដូច្នោះក៏កើតចិត្តស្រឡាញ់ស្នេហាដូចជាកូនកើតពីសាច់យ៉ាងនោះ ក្លែងខ្លួនឲ្យឃើញប្រាកដហើយសួរថា: — ភោ មាណវ ម្នាលមាណពដ៏ចំរើន! អ្នកឈ្មោះអ្វី ,,? — ,,កូននរណា ?,, មានការអ្វី? — នរណាបញ្ជូនអ្នកមក? ពោធិសត្វតបថា ,,យើងឈ្មោះធនញ្ជយកុមារ ជាបុត្រធនញ្ជយសេដ្ឋី ជាទាសបុត្រនៃព្រះបាទធនញ្ជយកោរព្យរាជ ព្រះអង្គបញ្ជូនយើងមកបានជាយើងមកដូច្នេះ ៗ — ,,ចុះមាណពឯងចេះមលតធម៌ដែរ ឬ? ,, ។ — ,,អ្នកឯងដឹងហើយតើយើងនេះស្តេចបញ្ជូនមកឲ្យអ្នកឯងបរិភោគជាចំណីអ្នក ,, ។ — ,,ទេ!... សាច់នឹងឈាមរបស់អ្នកតូចណាស់ មិនស្កប់នឹងធ្មេញខ្ញុំទេ យើងមិនស៊ីអ្នកឯងឡើយ មកចូលមកចុះ ,, ។ ពោធិសត្វចូលទៅក្រោមម្លប់ជ្រៃហើយឈរស្ងៀម ។ — ,,ម្តេចក៏មាណពឯងមិនចូលឲ្យដល់យើងមក,,? — ,,យើងកាន់សុចរិតធម៌បានជាមិនចូលដល់អ្នក! ,, — យី!.. ដូចម្តេចទៅសុចរិតធម៌សូមមាណពឯងថែងបន្តិចមើល? ។ អ្នកចាំស្តាប់ចុះដូច្នេះថា ៖

អនិមន្តំ ឃរំ គន្ត្វា អបុច្ឆា បរិភាសតិ អត្តានញ្ញ បសំសិយោ · តំវិធហីនលក្ខណំ សេចក្តីថា កិរិយាខាតលក្ខណ៍មាន ៣ យ៉ាងគឺ: គេមិនបាននិមន្ត ឬ អញ្ជើញឲ្យទៅផ្ទះគេហើយទៅកាន់ផ្ទះគេញយ ១, គេមិនបានសួរតាំងឆ្លើយស្រាវមុន១,

គេមិនទាន់សរសើរតាំងអ្នកសរសើរលើកគុណតែខ្លួនឯង១, ម្នាលយក្ស បុគ្គលលុះតែលះបង់ហីនលក្ខណ ទាំងបីនេះចេញឲ្យស្រឡះទើបឈ្មោះថា អ្នកប្រព្រឹត្តធម៌សុចរិតមែន ” ។

យក្សស្តាប់ហើយនឹកស្ងើចក្នុងចិត្តថា នេះបានជាបុរសអាជានេយ្យពិតប្រាកដមែន ទើបមានវាចាថា: «ខ្ញុំមិនដែលឮទេ ពីរោះណាស់ ខ្ញុំសូមបូជាដោយគ្រឿងសក្ការៈដល់អ្នក ហើយរៀបតែងធម្មាសនៈនិងសក្ការៈជាច្រើន មានទាំងស្លូត្រង់គ្រប់ទបាំង ហើយក៏ម៉ម៉ាហោះស្ទុះទៅដងទឹកអនោតត្រស្រះផ្ងូតជំរះកាយព្រះពោធិសត្វ ប្រស់ព្រំដោយគ្រឿងក្រអូបឈ្មុយឈ្ងុយទាំងចំណីជាទិព្វ ប្រដាប់ដោយគ្រឿងអលង្ការល្អអស្ចារ្យ ទើបអារាធនាអញ្ជើញព្រះពោធិសត្វឡើងលើធម្មាសនៈ សំដែងធម៌ទេសនា អំពីមលតរធម៌នោះ ។

ព្រះពោធិសត្វក៏តាំងចាប់យកផ្ទិតបទមុខប្រកាសឲ្យយក្សទទួលកល្យាណធម៌ជាមុនថា: គោ យក្ខរាជ! ម្នាលស្តេចយក្ស! អ្នកឯងប្រុងចាំទទួលកល្យាណធម៌ជាបទគាថាដូច្នេះថា:

បាណាតិបាតា ធនហារតាបិ បរស្សទានំ វចនំ អសច្ចំ មជ្ជំបិ វិយោ ឥធសោ នរោច បមូលប្បោ មុនិនា បវុត្តោ ។ សេចក្តីថា បុរសស្ត្រីណាក្នុងលោកនេះប្រព្រឹត្តសម្លាប់សត្វ១ លួចប្លន់ បំបាត់ប្រវញ្ចន៍បន្ទំ បោកបញ្ឆោតយកទ្រព្យគេ១ លួចប្រពន្ធគេ លួចប្តីគេ លួចកូនក្រមុំគេ១ និយាយកុហក១ ផឹកសុរា-មេរ័យ គឺស្រា.ទឹកត្នោតជូ ភាគៀនកញ្ឆាជាដើម១ នរណាប្រព្រឹត្តធ្វើអំពើទាំង៥នេះ ឈ្មោះថាជីករំលើងឬសគល់ខ្លួនឯងលែងបានកើតជាមនុស្សទៅទៀតហើយ នេះជាធម៌លាមកក្រៃលែង ។ (នៅមានត)

ព្រះមហាក្សត្រ តើអ្នកពាល់គ្នាព្រមសុខចិត្តចាញ់ទេ ដូចសំដីដើមរបស់អ្នកពាល់គ្នា ឬមិនព្រម ?

ពួកអាមាត្យ នៅទ្រឹងមួយសន្ទុះហើយ ទឹកក្នុងចិត្តថា បើឯងព្រមទទួលយកកំចាញ់វា បើមិនព្រមទទួលយកកំចាញ់វា ណ្ហើយបុះសព្វបើគ្រាន់តែការសុំចាញ់ប៉ុណ្ណោះ ត្រូវតែព្រមព្រោះថាបើទុកជាយើងព្រមសុខចិត្ត ក៏វានឹងធ្វើអីយើងមិនកើតដែរ ខ្ជាបអាក្ងន ប្រមកប៉ុណ្ណោះ ?

លុះគិតដូច្នេះហើយ អាមាត្យទាំងឡាយ ក្រាបបង្គំទូលទៅព្រះមហាក្សត្រវិញថា សូមទ្រង់ព្រះមេត្តាប្រោស ទូលព្រះបង្គំទាំងអស់គ្នាព្រមទទួលយកការសុំចាញ់ទៅនោះ តាមសំដីដើមហើយ ?

ព្រះមហាក្សត្រ ! អើ ! អាជ័យ ! ឥឡូវនេះគេព្រមទទួលហើយ តើអាឯងគិតធ្វើដូចម្តេច ?

កុមារជ័យ សូមទ្រង់ព្រះមេត្តាប្រោស ! បើអស់លោកព្រមទទួលយកការសុំចាញ់ទៅមែន ទូលព្រះបង្គំសុំបញ្ជូនតទៅទៀតថាត្រង់ពាក្យអស់លោកថា «ចាំមើលពេលក្រោយបើព្រះមហាក្សត្រគ្រាស់ហៅអាឯងឲ្យចូលមកទៀត នោះយើងប្រាកដជាសុំចាញ់អាឯងតែម្តង» ? ឥឡូវនេះអស់លោកសុំចាញ់ទេ ពាក្យនេះនឹងរ៉ាវុះមិនបាន ?

អម្បាលមិញនេះ ទូលព្រះបង្គំចេញទៅដល់ខាងក្រៅព្រះបរមពដ្ឋាំងហើយ ព្រះកត្តុណាវិថ្ងៃវិសេសទ្រង់គ្រាស់ឲ្យហៅចូលមកវិញ ក្រោយកិច្ចសន្យារបស់អស់លោកនឹងទូលព្រះបង្គំនេះ តើឈ្មោះថាព្រះអង្គទ្រង់គ្រាស់ឲ្យហៅទូលបង្គំចូលមកទៀតឬទេ ? ?

ព្រះមហាក្សត្រ យ៉ាងនេះពិតជាអញឲ្យហៅអាឯងចូលមកទៀត អ៊ុចឹងមែនហើយ ។

កុមារជ័យ បើដូច្នោះ តើត្រូវពួកអស់លោកទទួលយកការសុំទាញទទេឬយ៉ាងណា?។

ព្រះមហាក្សត្រ ត្រូវតែពួកអ្នកទាំងនេះ ទទួលយកការសុំទាញទទេនោះអ៊ុចឹងហើយ ។

កុមារជ័យ នែ! អស់លោកដូចម្ដេច ដែលគេហៅថាទាញទទេ ។

ពួកអាមាត្យ ដែលគេហៅថាទាញទទេ គឺទាញឥតមានដាក់អ្វីសោះ ។

កុមារជ័យ អ៊ីចឹងមែនហើយលោក ឯទាញទទេ គឺទាញឥតមានរឿងហេតុអ្វីសោះ ដូចជាបានទទេនោះដែរ ។ ដូច្នេះតាំងពីថ្ងៃនេះទៅ ត្រូវតែអស់លោកសុំទាញខ្ញុំទើបទុកជាការត្រឹមត្រូវបាន បើត្រឡប់ជាមិនទាញវិញ នោះទុកជាកុហកសមួយយ៉ាងធំ ។

ព្រះមហាក្សត្រ ទ្រង់ព្រះសម្រួល ហើយមានព្រះបន្ទូលថាអ៊ុចឹងមែនហើយ ពួកអាមាត្យត្រើមុខក្រៀមទាំងអស់គ្នា ។ កុមារជ័យក្រាបបង្គំលាព្រះមហាក្សត្រចេញទៅកាន់ផ្ទះរបស់ខ្លួនតាមប្រក្រតី ។

តាំងពីថ្ងៃនោះមកកុមារជ័យចេះតែដើរនិយាយប្រាប់អ្នកស្រុកអ្នកភូមិថា ពួកសេវ-មាត្យទាញខ្ញុំទាំងអស់ គ្មាននរណាឈ្នះខ្ញុំម្នាក់សោះ ខ្លួនឯងឈ្នះជ័យហើយ បានជ័យទៀត នេះហៅថាជ័យត្រួតលើជ័យ ។

ពាក្យនោះឮខ្ទរខ្ទារពេញព្រះរាជធានីទាំងមូល លឺថាកុមាជ័យឈ្នះអាមាត្យទាំងអស់ ។ អ្នកខ្លះនឹកឆ្ងល់ថា អាជ័យនេះវាឈ្នះពីរឿងអី ហើយទៅសួរពួកអាមាត្យខ្លះៗក៏ឆ្លើយប្រាប់មកវិញថា ណ្ហើយកុំបាច់សួរពីរឿងអាជ័យនោះធ្វើអី គ្មាននរណានិយាយជាមួយនឹងវាបានទេ ស្រេចតែនឹងវាថាដូចម្ដេចក៏ថាទៅ

ថ្ងៃក្រោយមកពួកអស់អ្នក នឹងពួកសេវកាមាត្យដង្ហែព្រះមហាក្សត្រគាត់ក្ដមទៅទីផ្សារ ។ ថ្ងៃនោះឯកទឹងកាណាទៅរាល កុមាជ័យបានក្រឡេកមើលទៅឃើញដង្ហែព្រះមហាក្សត្រមកពីចម្ងាយ ហើយរត់ឡើងមកលើផ្ទះ យកកំពោរលាបគូថហើយគូរធ្វើជាមុខ ។ គ្រាន់តែព្រះមហាក្សត្រទ្រង់យាងហួសផ្ទះខ្លួនបន្តិចទៅក៏ទយគូថតាមប្រហោងជញ្ជាំងមកក្ដាម ។ ពួកអស់អ្នកក្រឡេកមើលទៅឃើញមុខស្រមាមចេញក្ដែតមកដូច្នោះក៏នាំចង្អុលខ្វាត់ខ្វែងមាត់អ៊ូអឡើងថា សត្វអីនោះៗ លោតែចេញក្ដែតមកតាមប្រហោងជញ្ជាំងផ្ទះអាជ័យ មុខស្រមេមស្រមាមយ៉ាងនេះ សេចក្ដីច្របូលច្របល់នេះផ្អើលដល់អាមាត្យព្កុដល់ព្រះមហាក្សត្រៗក៏ទ្រង់ត្រាស់ឲ្យអាមាត្យឡើងទៅមើល

ពួកអាមាត្យបានឡើងទៅមើលឃើញកុមារជ័យគុនទយគូថតាមប្រហោងជញ្ជាំងក៏ចុះមកក្រាបបង្គំទូលព្រះមហាក្សត្រវិញ តាមដំណើរនោះ ។ ព្រះមហាក្សត្រទ្រង់សណ្ដាប់ហើយកំណត់ក្នុងព្រះទ័យទើបស្ដេចយាងហួសទៅ ។

លុះស្ដេចយាងត្រឡប់មកដល់ព្រះបរមរាជវាំងវិញ ទ្រង់ត្រាស់ប្រើអាមាត្យឲ្យទៅហៅកុមារជ័យមកដល់ហើយ ទ្រង់មានព្រះបន្ទូលសួរថា នែ! អាជ័យ! ហេតុអ្វីក៏អាឯងគូរក្រប៉េះគូថទយតាមប្រហោងជញ្ជាំងបង្ហាញអញយ៉ាងនេះ ។

កុមារជ័យ.– សូមទ្រង់ព្រះមេត្តាប្រោស! កាលដែលព្រះអង្គស្ដេចយាងដល់ផ្ទះទូលព្រះបង្គំ ទ្រង់បានធ្មៀងព្រះនេត្រទតផ្ទះទូលព្រះបង្គំដែរឬទេ ?

ព្រះមហាក្សត្រ.– អញក្រឡេកមើលទៅដែរ ។

កុមារជ័យ.– ចុះព្រះអង្គបានឃើញទូលព្រះបង្គំធ្វើដូច្នោះឬមិនឃើញ ។

ព្រះមហាក្សត្រ.– អញមិនឃើញទេ ។

កុមារដ៏យ.— បពិត្រមហាពល! ចុះអ្នកណាឃើញទូលព្រះបង្គំធ្វើដូច្នោះ ?

ព្រះមហាក្សត្រ.— អញមិនដឹងជាអ្នកណាឃើញដែរ ស្រាប់តែ ពួ មាត់អ្ហ្ការឡើង ទើបអញប្រើគាមាត្យឲ្យទៅមើល ?

កុមារដ៏យ.— បើដូច្នោះ សូមព្រះអង្គត្រាស់ហៅអ្នកទាំងអស់នោះមក ហើយមានព្រះបន្ទូលសួរមើល តើអ្នកណាបានឃើញមុនគេ ?

ព្រះមហាក្សត្រទ្រង់ត្រាស់ឲ្យហៅពួកសេវាគាមាត្យទាំងនោះមកហើយ ទ្រង់ត្រាស់សួរហ្ចូរហ្ចារទៅឃើញថា ពួកអស់អ្នកឃើញមុនគេ ទើបទ្រង់មានបន្ទូលសួរទៅកុមារដ៏យថា នែ! អាដ៏យ! ឥឡូវនេះពួកអស់អ្នកគេនិយាយថា គេឃើញមុនគេ ?

កុមារដ៏យ.— បពិត្រ! ព្រះសម្ចាស់ទេព សូមទ្រង់បាត់រាជការឲ្យស្បថជាមុនសិនសឹមឲ្យនិយាយរឿងប៉ាន់ប៉ីពីការឃើញនូវអំពើរបស់ទូលព្រះបង្គំ ទើបចម្លើយនោះទៀងត្រង់?

ព្រះមហាក្សត្រ.— បើដូច្នោះ ត្រូវអ្នកទាំងអស់ទៅធ្វើសម្បថ ចំពោះមុខអ្នកតាដ៏បង់ដែក ឯដើមប្រកាច់ប្រជានោះសិនទើបមកនិយាយបញ្ជាក់ចុះ ចំណែកខាងអាដ៏យវិញ ក៏ស្បថដែរ ?

ពួកសេវាគាមាត្យ ទាំងពួកអស់អ្នក នាំគ្នាទៅស្បថចំពោះមុខអ្នកតាដ៏បង់ដែក ឯដើមប្រកាច់ប្រជានោះ កុមារដ៏យក៏ទៅស្បថជាមួយទាំងគេដែរ ?

ក្រោយពេលដែលស្បថហើយ ក៏នាំគ្នាចូលមកកាន់សណ្ឋាគ ព្រះមហាក្សត្រ ? ទ្រង់ត្រាស់សួរបញ្ជាក់ទៅពួកអស់អ្នកអំពីដំណើរដែលឃើញតើមានសភាពយ៉ាងណា ? ?

ពួកអស់អ្នកក៏ក្រាបបង្គំទូលតាមពិតថា បពិត្រព្រះសម្ចាស់ទេព នៅវេលាដែលទ្រង់ស្តេចយាងហ្ចូលបន្ទូចទៅ ស្រាប់តែទូលព្រះបង្គំឃើញមុខស្រមើមស្រមៃមកបញ្ជ្រៃកូតតាមប្រហោងជញ្ជាំងផ្ទះអាដ៏យ ទូលព្រះបង្គំនឹកភ័យភ្ញាត់ភ្ញាត់ក្បាលមួយរំពេច

នោះ ព្រោះក្រែងខ្ញុំចលងទាំងដៃ លុះឮដល់ពួកសេវ៉ាកាមាត្យ ។ ក៏ក្រាបបង្គំទូលព្រះអង្គ ។ ក៏ទ្រង់ចាត់ការឲ្យទៅមើលឃើញពិត ហើយនាំសេចក្ដីមកក្រាបបង្គំទូលវិញ ។

ព្រះមហាក្សត្រ នែ! នាយ! ដែលអញប្រើឯងឲ្យទៅមើលនោះឯងឃើញពិតជាអាដ័យវ៉ាធ្វើដូច្នោះមែនឬ? ។

ពួកសេវ៉ាកាមាត្យ សូមទ្រង់ព្រះមេត្តាប្រោស ឃើញអាដ័យវ៉ាធ្វើដូច្នោះមែន ។

ព្រះមហាក្សត្រ ចុះអាដ័យ! ឯងធ្វើដូច្នោះមែនឬ? ។

កុមារដ័យ សូមទ្រង់ព្រះមេត្តាប្រោស ទូលព្រះបង្គំបានធ្វើដូច្នោះមែន ។

ព្រះមហាក្សត្រ អាឯងធ្វើយ៉ាងនេះដោយមានបំណងយ៉ាងណា ។

កុមារដ័យ សូមទ្រង់ព្រះមេត្តាប្រោស ទូលព្រះបង្គំមានចិត្តរលឹកព្រះអង្គ, នឹងរលឹកពួកសេវ៉ាកាមាត្យ, ទឹកមានចិត្តនឹករលឹកអ្នកបងទាំងអស់ពន់ពេក ។ លុះទ្រង់ស្តេចយាងមកដល់ផ្ទះទូលព្រះបង្គំលបែរមើលតាមប្រហោងតូចនៃជញ្ជាំងផ្ទះ ។ កាលទ្រង់ស្តេចយាងផុតទៅភ្លាម ពួកអស់អ្នកទាំងនេះមកដល់ទូលព្រះបង្គំមិនហ៊ានអើតមុខមើល ព្រោះកាលពីថ្ងៃមុន ធ្លាប់ស្រដីចំពោះទូលព្រះបង្គំថា ស្ងប់មុខអាដ័យ ណាស់ ។ កាលណោះទូលព្រះបង្គំធ្លាប់បញ្ជាក់ទៅអ្នកបងទាំងនោះវិញថា បើប្រាកដជាស្ងប់មុខមែន នឹងមានការធ្វើខ្ជិនខ្ជ ព្រោះតែស្ងប់មុខនោះឯង ហេតុនេះធ្លាប់ជាទូលព្រះបង្គំគ្រូ ក្រពើងគ្ងមជ្ជើជាមុខនុនទយមើលអ្នកបងទាំងអស់នោះ តាមប្រហោងជញ្ជាំង ព្រោះមិនហ៊ានបង្ហាញមុខ ក្រែងអ្នកបងស្ងប់មុខដូចមុនទៀត ។

ព្រះមហាក្សត្រ លុះទ្រង់ព្រះសណ្ដាប់សេចក្ដីក្រាបបង្គំទូលនៃកុមារដ័យ យ៉ាងនេះ ទ្រង់ត្រាស់សួរបញ្ជាក់ទៅពួកអស់អ្នកទាំងនោះវិញថា នាងទាំងឡាយ ធ្លាប់និយាយ ដូច្នោះមែនឬ? ។

(នៅមានត)

ពាក្យប្ចីរបស់គណកម្មការវិជ្ជធម៌ ដែលប្រែចេញពីភាសាបារាំង

Jumenterie des F.A.R.K.	ទីបង្គាត់សេះនៃ ស.ខ.ក.
Jeunesse	យុវជន
Jurés	មេប្រយោគ
La boratoire micrologie	ទីពិសោធន៍អតិសុខុមជីវសាស្ត្រ
Lauréats	ជ័យលាភី
Letire de change	រូបិយណត្តិ លិខិតដែលឈ្មោះកម្ចីប់
	ឈ្មោះ ១ ឲ្យបើកប្រាក់ឲ្យឈ្មោះ ត
Lettre valant marché	សមាគមលិខិត
Libollé des opérations	ឫយពាក់ប្រតិបត្តិការ
Linguistique général	ភាសាសាស្ត្រទូទៅ
Livre auxiliaire	សៀវភៅជំនួយ
Livre de compte	សៀវភៅគណនី
Livre journal	សៀវភៅប្រចាំថ្ងៃ
Logique	តក្កវិជ្ជាតក្កវិទ្យា
Main d'œuvre	ហត្ថពល-ហត្ថ-លិត-ហត្ថមូល
Marche	យាត្រា
Marché	ផ្សារ អាបណាសញ្ញា សញ្ញាលក់ទិញ
Maréchél jerrant	ជាងរបាំងក្រចកសេះ

Maréchalerie	ពោធិ៍ជាងធ្វើចុះក្រចកសេះ
Médecinchef	គ្រូពេទ្យនាយ
Médecintraibent	គ្រូពេទ្យព្យាបាល
Miss combodge	បវរកញ្ញាកម្ពុជា
Monument	វិមាន
Norme	ធម្មនិយាមបង្ហាញគោលការណ៍ដែលទុកជាវិធាន
Nomade	អ្នកស្នាក់អណ្តែត
Notice	និវេទន៍-វិញ្ញាណាប័ន
Notification	ប្រកាសន៍ វិញ្ញាប័ន-វិញ្ញត្តិ ការឲ្យដំណឹង ជាលាយលក្ខណ៍អក្សរ
Nouvelle	ប្រតិបត្តិការ ដំណឹង
Office national des changes	ជាតិមន្ទីរប្តូរប្រាក់

វចនានុក្រមវិទ្យាសាអង់គ្លេស (ត)

1 -They coudn't (ឃូដ-ដឺនត៍) pay the rent, so the landlord TURNED THEM OUT.	អ្នកទាំងនោះពុំអាចបង់ថ្លៃឈ្នួលបាន, ព្រោះហេតុនោះម្ចាស់ផ្ទះដេញចេញ ។
2- It was cloudy this morning,	ព្រឹកនេះមេឃងងឹត, ប៉ុន្តែត្រឡប់

but it TURNED OUT fine.

3- Althongh it looked like rain this morning, il TURNED OUT to be a fine day.

4- Hari has TURNED OUT to be the best student in our English class,

5- She TURS OUT one room every day.

VII- TO TAKE INTO ACCOUNT; (to take into consideration)

1- In judging her work, you should TAKE INTO ACCOUNT that she has been quite sick recently.

2- He never TAKES INTO ACCOUNT the faet that I am very busy.

VIII- TO SMELL; (to have bad ordour; to perceive any ordour)

ជាស្រឡះធ្លាយទៅវិញ ។

សូម្បីហាក់ដូចជាវាកកល់ភ្លៀងព្រឹកនេះ, ក៏ចាន់ត្រឡប់ទៅជាស្រឡះធ្លាយទៅវិញ ។

កុមារ ហារី ចាន់ត្រឡប់ទៅជាសិស្សពូកែធ្លឹម ក្នុងថ្នាក់រៀនអង់គ្លេសរបស់យើង ។

នាងនោះតែង ចេញសំអាតបន្ទប់ម្ដងៗក្នុងមួយថ្ងៃ ។

លើកយកមកពិចារណា;

ក្នុងការវិនិច្ឆ័យនូវកិច្ចការរបស់នាង, គួរណាកលើកយកមកពិចារណា នូវហេតុថា នាងចាន់ឈឺធ្ងន់ក្នុងពេលថ្មីៗនេះ ។

យើងមិនដែលលើកយកមកពិចារណានូវសេចក្ដីពិតថា ខ្ញុំជាអ្នកវល់ខ្លាំង (ដូច្នេះសោះ)

មានក្លិនគាស្រ្ដក់; ហិតក្លិន; ធំក្លិន;

1- Take that chcese away, it SMELLS.

2- I woke up with a start, I coule SMELL fire.

យកព្រហ្មាក់ចាវ៉ាន់នោះចេញ, វាធំ ក្លិនអាក្រក់ (ស្អុយ) ។

ខ្ញុំស្ទុះក្រោកឡើង, ខ្ញុំធំក្លិនភ្លើងនេះ ។

NOTE: ពាក្យ «smell» បើប្រើបំពោះក្លិនអាក្រក់ មិនចាប់បញ្ចូលពាក្យដទៃមកជាជំនួយក៏ចាន ព្រោះពាក្យនេះអាចឲ្យអត្ថន័យថា «ធំក្លិនអាក្រក់»; បើចង់ឲ្យច្បាស់លាស់, បញ្ចូលពាក្យដទៃមកជាជំនួយក៏ចាន; ដូច: it smell bod (វាធំ, ក្លិនអាក្រក់) ។

បើប្រើបំពោះវត្ថុមានក្លិនល្អត្រូវតែបញ្ចូលពាក្យដទៃមកជាជំនួយ; ដូច: the rose smells sweet (ផ្កាកូឡាបមានក្លិនក្រអូបឆ្ងាញ់)

IX- TO TAKE A LOOK At; (to look at)

1- TAKE A LOOK AT the hat Hari is wearing to-day.

2- He TOOK A LOOK AT her and began to laugh.

មើល; សំឡឹងមើល; ក្រឡេកមើល; ចូរមើលមួក ដែលហារីពាក់ថ្ងៃនេះ ។

គាត់ចាន់ក្រឡេកមើលនាងហើយចាប់ផ្តើមសើច ។

X- TO FALL TO; (ta commence; to commence to eat; to become a duty.)

1- A s soon as the work was distributed, each man FELL To..

2- He FELL TO raveniously.

3- It FELL TO me to tell him.

ចាប់ផ្តើម(ធ្វើ) ផ្តើមបរិភោគ; ជានាទី; ការដែលគេចាន់ចែកការងារហ្ចូរហើយ ចូរសម្លាញ់ៗក៏ចាន់ចាប់ផ្តើមធ្វើ ។

គាត់ចាប់ផ្តើមបរិភោគយ៉ាងឃ្លុកឃ្លាក ។

នោះគឺជានាទីរបស់ខ្ញុំត្រូវប្រាប់គាត់ ។

(នៅមានត)

កោដ្ឋកម្ពុជវិយ
ទៅតាមក្បួនជ្រោមអូរឬស្សីសង្កាត់លេខ៥